# សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធី

## ផ្នែក B នៃច្បាប់ស្តីពីការសិក្សាអប់រំបុគ្គលមានពិការភាព (IDEA).

*កំណត់សំគាល់: សេចក្តីយោងទាំងអស់ចំពោះមណ្ឌលអប់រំ គឺអាចអនុវត្តបានចំពោះទីភ្នាក់ងារសាធារណៈមានសមត្ថកិច្ច ។*

## តារាងមាតិការ

**ពត៌មានទូទៅ** ..... **1**
សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ..... 1
ភាសាកំណើត ..... 2
សំបុត្រអេឡិចត្រូនិក ..... 2
ការយល់ព្រមរបស់មាតាបិតា – និយមន័យ ..... 2
ការយល់ព្រមរបស់មាតាបិតា ..... 3
ការវាយតំលៃអប់រំដោយឯករាជ្យ ..... 5

**ការរក្សាការសម្ងាត់នៃពត៌មាន** ..... **7**
និយមន័យ ..... 7
ពត៌មានដែលអាចសំគាល់អត្តសញ្ញាណបុគ្គលបាន ..... 7
សេចក្តីជូនដំណឹងចំពោះមាតាបិតា ..... 7
សិទ្ធិក្នុងការចូលពិនិត្យ ..... 8
កំណត់ត្រានៃការចូលពិនិត្យ ..... 8
ឯកសារអំពីកុមារលើសពីម្នាក់ ..... 8
បញ្ជីប្រភេទនិងទីកន្លែងនៃពត៌មាន ..... 9
ការបង់ប្រាក់ ..... 9
ការកែប្រែឯកសារតាមសំណើមាតាបិតា ..... 9
ឱកាសមានសវនាការ ..... 9
នីតិវិធីសវនាការ ..... 9
លទ្ធផលនៃសវនាការ ..... 9
ការយល់ព្រមឲ្យបញ្ចេញពត៌មានដែលអាចសំគាល់បុគ្គលបាន ..... 10
កិច្ចការពារ ..... 10
ការបំផ្លាញចោលពត៌មាន ..... 11

**នីតិវិធីបណ្តឹងរដ្ឋ** ..... **11**
ភាពខុសគ្នារវាងបណ្តឹងតាមនីតិវិធីត្រឹមត្រូវតាមច្បាប់ និងនីតិវិធីបណ្តឹងរដ្ឋ ..... 11
ការអនុវត្តន៍នីតិវិធីបណ្តឹងរដ្ឋ ..... 11

*នីតិវិធីអប្បបរិមានៃបណ្តឹងរដ្ឋ* ..... 12
*ការដាក់ពាក្យបណ្តឹង* ..... 13

**នីតិវិធីបណ្តឹងត្រឹមត្រូវតាមច្បាប់ ..... 14**
*ការដាក់ពាក្យបណ្តឹងត្រឹមត្រូវតាមច្បាប់* ..... 14
*បណ្តឹងត្រឹមត្រូវតាមច្បាប់* ..... 14
*ពាក្យបណ្តឹងគំរូ* ..... 16
*ការសម្រុះសម្រួល* ..... 16
*ដំណើរការសវនាការ* ..... 17

**សវនាការលើបណ្តឹងត្រឹមត្រូវតាមច្បាប់ ..... 19**
*សវនាការត្រឹមត្រូវតាមច្បាប់មិនលំអៀង* ..... 19
*សិទ្ធិសវនាការ* ..... 20
*សេចក្តីសំរេចនៃសវនាការ* ..... 21

**បណ្តឹងឧទ្ធរណ៍ ..... 22**
*ទីបញ្ចប់នៃសេចក្តីសំរេច; បណ្តឹងឧទ្ធរណ៍; ការពិនិត្យឡើងវិញដោយមិនលំអៀង* ..... 22
*ពេលវេលាកំណត់និងភាពងាយស្រួលនៃសវនាការនិងការពិនិត្យឡើងវិញ* ..... 22
*បណ្តឹងរដ្ឋប្បវេណី, រួមទាំងរយៈពេលដែលត្រូវដាក់បណ្តឹងទាំងនោះ* ..... 23
*ការដាក់កុមារក្នុងសាលានៅពេលដែលសវនាការនិងបណ្តឹងត្រឹមត្រូវតាមច្បាប់មិនទាន់សំរេច* ..... 24
*ថ្លៃឈ្នួលមេធាវី* ..... 24

**នីតិវិធីពេលដាក់វិន័យកុមារដែលមានពិការភាព ..... 26**
*អំណាចបុគ្គលិកសាលា* ..... 26
*ការផ្លាស់ប្តូរសាលាដោយមូលហេតុត្រូវដកចេញដោយសារខុសវិន័យ* ..... 29
*ការកំណត់ទីកន្លែងសិក្សា* ..... 29
*បណ្តឹងឧទ្ធរណ៍* ..... 29
*ការដាក់កុមារក្នុងស្ថាប័នសិក្សាក្នុងពេលបណ្តឹងឧទ្ធរណ៍* ..... 30
*ការការពារសំរាប់កុមារដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់ទទួលសេវាអប់រំពិសេស និងសេវាទាក់ទិនផ្សេងទៀត* ..... 31
*ការបញ្ជូនទៅ និងវិធានការដោយរដ្ឋអំណាចពង្រឹងច្បាប់និងតុលាការ* ..... 32

**តម្រូវការនានាសំរាប់ការដាក់កូនក្នុងសាលាឯកជនដោយចំណាយលុយរដ្ឋ ដោយមាតាបិតាជាឯកតោភាគី ..... 32**
*ទូទៅ* ..... 32

# ពត៌មានទូទៅ

## សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន

## 34 CFR §300.503

### *សេចក្តីជូណដំណឹង*

*មណ្ឌលអប់រំរបស់អ្នកត្រូវផ្តល់ដល់អ្នកនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ (ផ្តល់ពត៌មានផ្សេងៗដល់អ្នកតាមលិខិត), ជាមួយពេលវេលាដ៏គ្រប់គ្រាន់ និង សមរម្យមួយ:*

1. *ស្នើផ្តើម ឬស្នើប្តូរអត្តសញ្ញាណកម្ម, ការវាយតំលៃ, ឬការដាក់កូនអ្នកក្នុងស្ថាប័នសិក្សា, ឬការផ្តល់ការសិក្សាអប់រំសាធារណៈដោយឥតគិតថ្លៃ*(FAPE) *ដល់កូនអ្នក;* ***ឬ***
2. *មិនព្រមផ្តើម ឬប្តូរអត្តសញ្ញាណកម្ម, ការវាយតំលៃ, ឬការដាក់កូនអ្នកក្នុងស្ថាប័នសិក្សា, ឬការផ្តល់* FAPE *ដល់កូនអ្នក ។*

### *មាតិការនៃសេចក្តីជូនដំណឹង*

*សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរត្រូវតែ:*

1. *រៀបរាប់អំពីវិធានការដែលមណ្ឌលអប់រំអ្នកស្នើ ឬមិនព្រមធ្វើ;*
2. *ពន្យល់ពីមូលហេតុដែលមណ្ឌលអប់រំអ្នកកំពុងស្នើឬមិនព្រមចាត់វិធានការ;*
3. *រៀបរាប់អំពីនីតិវិធីនៃការវាយតំលៃ, ការធ្វើតេស្ត, ឯកសារ, ឬរបាយការណ៍និមួយៗ ដែលមណ្ឌលអប់រំអ្នកប្រើក្នុងការសំរេចស្នើឬមិនព្រមចាត់វិធានការ;*
4. *មានសេចក្តីបញ្ជាក់ថា អ្នកមានការការពារក្រោមមាត្រាស្តីពីកិច្ចការពារតាមនីតិវិធី មានក្នុងផ្នែក* B *នៃច្បាប់* IDEA;
5. *ប្រាប់អ្នកអំពីវិធីដែលអ្នកអាចរកបានឯកសារកិច្ចការពារតាមនីតិវិធី ប្រសិនបើវិធានការដែលមណ្ឌលអប់រំអ្នកកំពុងស្នើឡើង ឬកំពុងមិនអនុវត្ត មិនមែនជាសេចក្តីយោងលើកដំបូងសំរាប់ការវាយតំលៃ;*
6. *មានពត៌មានសំរាប់អ្នកទាក់ទងរកជំនួយដើម្បីយល់ដឹងផ្នែក* B *នៃច្បាប់* IDEA;
7. *រៀបរាប់អំពីជម្រើសដទៃផ្សេងទៀតដែលក្រុមកម្មវិធីអប់រំសំរាប់បុគ្គល*(IEP) *បានពិចារណា និងមូលហេតុដែលជម្រើសទាំងនោះត្រូវបានច្រានចោល;* ***និង***
8. *ផ្តល់នូវសេចក្តីពិពណ៌នាអំពីមូលហេតុដទៃទៀតដែលធ្វើឲ្យមណ្ឌលអប់រំអ្នកស្នើ ឬបដិសេធវិធានការនោះ ។*

### *សេចក្តីជូនដំណឹងជាភាសាដែលអាចយល់បាន*

*សេចក្តីជូនដំណឹងត្រូវតែ:*

1. *សរសេរជាភាសាដែលសាធារណៈជនទូទៅអាចយល់បាន;* ***និង***
2. *ផ្តល់ឲ្យជាភាសាកំណើតរបស់អ្នក ឬវិធីទំនាក់ទំនងដទៃទៀតដែលអ្នកប្រើ, លើកលែងតែមិនអាចធ្វើដូច្នេះទៅបានដោយជាក់ស្តែង ។*

*ប្រសិនបើភាសាកំណើតរបស់អ្នកឬវិធីទំនាក់ទំនងដទៃទៀតជាភាសាគ្មានអក្សរ, មណ្ឌលអប់រំអ្នកត្រូវធានាថា:*

1. *សេចក្តីជូនដំណឹងត្រូវប្រែសំរួលជូនអ្នកផ្ទាល់មាត់ រឺ តាមមធ្យោបាយផ្សេងៗទៀត ជាភាសាកំណើតរបស់អ្នក ឬវិធីទំនាក់ទំនងដទៃ ទៀត;*
2. *អ្នកយល់ពីមាតិការនៃសេចក្តីជូនដំណឹង;* ***និង***
3. *មានភស្តុតាងជាលាយលក្ខណ៍អក្សរថា ចំនុចទី 1 និងទី 2 ត្រូវបានសំរេច ។*

# *ភាសាកំណើត*

## 34 CFR §300.29

*ភាសាកំណើត, ពេលប្រើជាមួយបុគ្គលដែលមិនស្ទាត់ភាសាអង់គ្លេស, មានន័យដូចតទៅ:*

1. *ភាសានោះជាធម្មតាប្រើដោយបុគ្គលនោះ, ឬ, ក្នុងករណីកុមារ, ជាភាសាដែលធម្មតាប្រើដោយឪពុកម្តាយកុមារនោះ ។*
2. *ក្នុងរាល់ទំនាក់ទំនងដោយផ្ទាល់ជាមួយកុមារ (រួមទាំងការវាយតំលៃលើកុមារនោះផង), ភាសានោះជាធម្មតាប្រើដោយកុមារនោះនៅឯផ្ទះ ឬក្នុងបរិយាកាសសិក្សា ។*

*សំរាប់បុគ្គលថ្លង់ឬងងឹតភ្នែក, ឬសំរាប់បុគ្គលដែលគ្មានភាសាសរសេរ, វិធីទំនាក់ទំនងគឺអ្វីដែលបុគ្គលនោះប្រើជាធម្មតា (ដូចជាភាសាសញ្ញា, អក្សរសំរាប់មនុស្សខ្វាក់, ឬទំនាក់ទំនងផ្ទាល់មាត់) ។*

# *សំបុត្រអេឡិចត្រូនិក*

## 34 CFR §300.505

*ប្រសិនបើមណ្ឌលអប់រំអ្នកផ្តល់ជំរើសដល់មាតាបិតាក្នុងការទទួលឯកសារតាមអ៊ីម៉េល(e-mail), អ្នកអាចជ្រើសរើសទទួលឯកសារដូចខាងក្រោមនេះតាមអ៊ីម៉េល:*

1. *សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន;*
2. *សេចក្តីជូនដំណឹងស្តីពីកិច្ចការពារតាមនីតិវិធី;* ***និង***
3. *សេចក្តីជូនដំណឹងទាំងឡាយ ទាក់ទងនឹងបណ្តឹងត្រឹមត្រូវតាមច្បាប់មួយ ។*

# *ការយល់ព្រមរបស់មាតាបិតា – និយមន័យ*

## 34 CFR §300.9

***ការយល់ព្រម***

*ការយល់ព្រម* មានន័យថា:

1. *អ្នកត្រូវបានគេផ្តល់ឲ្យយ៉ាងពេញលេញជាភាសាកំណើតរបស់អ្នក ឬវិធីទំនាក់ទំនងដទៃទៀត (ដូចជា ភាសាសញ្ញា, ភាសាសំរាប់មនុស្សខ្វាក់, ឬទំនាក់ទំនងផ្ទាល់មាត់) នូវរាល់ពត៌មានទាំងអស់អំពីវិធានការដែលអ្នកកំពុងផ្តល់ការយល់ព្រម ។*
2. *អ្នកយល់និងយល់ព្រមជាលាយលក្ខណ៍អក្សរចំពោះវិធានការនោះ, ហើយការយល់ព្រមនេះរៀបរាប់អំពីវិធានការនោះ ព្រមទាំងរាយឈ្មោះឯកសារនានា (បើមាន) ដែលនឹងត្រូវបញ្ចេញ និងអ្នកដែលត្រូវបញ្ចេញឲ្យ;* ***និង***
3. *អ្នកយល់ ថាការយល់ព្រមនេះគឺដោយស្ម័គ្រចិត្តដោយខ្លួនអ្នក ហើយអ្នកអាចដកចេញការយល់ព្រមរបស់អ្នកវិញពេលណាក៏បាន ។*

*ប្រសិនបើអ្នកបញ្ឈប់ការយល់ព្រមបន្ទាប់ពីបុត្ររបស់អ្នកចាប់ផ្តើមទទួលការអប់រំពិសេស និង សេវាដែលពាក់ព័ន្ធ, អ្នកត្រូវធ្វើជាលាយល័ក្ខអក្សរ។ ការដកចេញវិញនូវការយល់ព្រមរបស់អ្នក មិនធ្វើឲ្យវិធានការដែលកើតមានរួចហើយក្រោយពេលអ្នកបានផ្តល់ការយល់ព្រម និង មុនពេលអ្នកបានដកវាចេញ ទៅជាឥតប្រយោជន៍នោះឡើយ ។ ថែមទៀតនោ:, មណ្ឌលអប់រំមិនតំរូវអោយកែតំរូវនូវកំណត់ត្រាអប់រំ*

*របស់បុត្រអ្នកដើម្បីលុបចោលនូវឯកសារយោងទាំងឡាយណាដែលបុត្ររបស់អ្នកបានទទួល ការអប់រំពិសេស និង សេវាដែលពាក់ព័ន្ធ បន្ទាប់ពីអ្នកបញ្ឈប់ការយល់ព្រម។*

# *ការយល់ព្រមរបស់មាតាបិតា*

## 34 CFR §300.300

### *ការយល់ព្រម សំរាប់ការវាយតំលៃលើកដំបូង*

*មណ្ឌលអប់រំអ្នកមិនអាចធ្វើការវាយតំលៃកូនអ្នកជាលើកដំបូង ដើម្បីកំណត់ថាតើកូនអ្នក ក្រោមផ្នែក* B *នៃច្បាប់* IDEA *មានសិទ្ធិទទួល សេវាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀតដែរឬទេ ដោយមិនផ្តល់ដល់អ្នកជាបឋមនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនឲ្យ ដឹងពីវិធានការដែលបានស្នើឡើង និងដោយគ្មានស្វែងរកការយល់ព្រមរបស់អ្នកដូចដែលបានរៀបរាប់ក្នុងជំពូក* ***ការជូនដំណឹងជាមុនជាលាយលក្ខ័អក្សរ*** និង ***ការយល់ព្រមរបស់ មាតាបិតា*** នោះឡើយ ។

*មណ្ឌលអប់រំអ្នកត្រូវតែធ្វើការខិតខំប្រឹងប្រែងឲ្យបានសមស្រប ដើម្បីស្វែងរកការយល់ព្រមប្រកបដោយពត៌មានពេញលេញរបស់អ្នក សំរាប់ការវាយតំលៃលើកដំបូងមួយ ដើម្បីសំរេចថាតើ កូនអ្នកគឺជាកុមារមានពិការភាពឬទេ ។*

*ការយល់ព្រមរបស់អ្នកសំរាប់ការវាយតំលៃជាលើកដំបូង មិនមានន័យថា អ្នកបានផ្តល់ការយល់ព្រមរបស់អ្នក ឲ្យមណ្ឌលអប់រំចាប់ផ្តើម ផ្តល់សេវាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀត ដល់កូនអ្នកឡើយ ។*

*បើកូនអ្នកកំពុងរៀននៅសាលារដ្ឋ ឬបើអ្នកកំពុងរកចុះឈ្មោះកូនអ្នកឲ្យរៀននៅសាលារដ្ឋហើយអ្នកបានបដិសេធមិនផ្តល់ការយល់ព្រម ឬខកខានមិនបានឆ្លើយតបដល់សំណើសុំឲ្យផ្តល់ការយល់ព្រមសំរាប់ការវាយតំលៃជាលើកដំបូងមួយ នោះមណ្ឌលអប់រំអ្នកអាច, ប៉ុន្តែមិន ចាំបាច់ឡើយ, ប្រឹងប្រែងធ្វើការវាយតំលៃជាលើកដំបូងមួយ ដោយប្រើប្រាស់ការសម្រុះសម្រួលនៃច្បាប់ ឬបណ្តឹងត្រឹមត្រូវតាមច្បាប់, ការជួបប្រជុំរកដំណោះស្រាយ, និងនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់មិនលំអៀង (លើកលែងតែតម្រូវឲ្យធ្វើដូច្នេះ ឬហាមធ្វើដូច្នេះ ក្រោមច្បាប់រដ្ឋ) ។ មណ្ឌលអប់រំអ្នកនឹងមិនរំលោភកាតព្វកិច្ចរបស់ខ្លួនក្នុងការរកកន្លែងរៀន, ធ្វើអត្តសញ្ញាណកម្ម និងវាយតំលៃកូនអ្នក ឡើយ ប្រសិនបើខ្លួនមិនបន្តធ្វើការវាយតំលៃកូនអ្នកក្នុងកាលៈទេសៈទាំងនេះ, លើកលែងតែច្បាប់រដ្ឋតម្រូវឲ្យខ្លួនបន្តធ្វើការវាយតំលៃនោះ ។*

### *បទបញ្ញត្តិពិសេសសំរាប់ការវាយតំលៃជាលើកដំបូងចំពោះកុមារដែលគេគ្រប់គ្រង*

*ប្រសិនបើកុមារម្នាក់ជាកុមារដែលគេគ្រប់គ្រង ហើយមិនរស់នៅជាមួយមាតាបិតាខ្លួន —*

*មណ្ឌលអប់រំមិនចាំបាច់ការយល់ព្រមពីមាតាបិតា សំរាប់ការវាយតំលៃជាលើកដំបូងដើម្បីកំណត់ថាតើកុមារនោះជាកុមារដែលមាន ពិការភាពដែរឬទេ ប្រសិនបើ:*

1. *បើទោះបីជាមានការខិតខំប្រឹងប្រែងដ៏សមស្របដើម្បីធ្វើដូច្នោះក្តី, មណ្ឌលអប់រំនៅតែមិនអាចរកមាតាបិតាកុមារនោះឃើញ;*
2. *សិទ្ធិនៃមាតាបិតាត្រូវបានបញ្ចប់យោងតាមច្បាប់រដ្ឋ;* ***ឬ***
3. *ចៅក្រមបានផ្តល់សិទ្ធិសំរេចក្នុងការទទួលការសិក្សាអប់រំនិងផ្តល់ការយល់ព្រមសំរាប់ការវាយតំលៃជាលើកដំបូង ទៅឲ្យបុគ្គល ណាម្នាក់ក្រៅពីមាតាបិតា ។*

*កុមារដែលគេគ្រប់គ្រង, ដូចបានប្រើក្នុងច្បាប់* IDEA*, មានន័យថា កុមារម្នាក់, ដូចបានកំណត់ដោយរដ្ឋនូវទីកន្លែងដែលកុមារនោះរស់នៅ, ដែល:*

1. *ជាកូនចិញ្ចឹម;*
2. *ចាត់ទុកថាជាកុមារដែលគេគ្រប់គ្រង ក្រោមច្បាប់រដ្ឋ;* ***ឬ***
3. *ស្ថិតក្នុងការគ្រប់គ្រងនៃទីភ្នាក់ងាររដ្ឋសង្គ្រោះកុមារ ។*

*ការលើកលែងមួយដែលអ្នកគួរដឹង។ កុមារដែលគេគ្រប់គ្រង* មិនរាប់បញ្ចូលកូនចិញ្ចឹមដែលមានឪពុកម្តាយចិញ្ចឹមដែលមានដូចចែងក្នុង និយមន័យមាតាបិតាដែលបានប្រើក្នុង IDEA *នោះឡើយ ។*

### *ការយល់ព្រមរបស់មាតាបិតា សំរាប់ការផ្តល់សេវាកម្មទាំងនោះ*

*មណ្ឌលអប់រំអ្នកត្រូវតែទទួលការយល់ព្រមរបស់អ្នក មុននឹងផ្តល់សេវាសិក្សាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀតដល់កូនអ្នកជាលើកទីមួយ ។*

*មណ្ឌលអប់រំត្រូវតែខិតខំប្រឹងប្រែងឲ្យបានសមស្រប ដើម្បីទទួលការយល់ព្រមរបស់អ្នក មុននឹងផ្តល់សេវាសិក្សាអប់រំពិសេស និងសេវាទាក់ទិនដទៃទៀត ដល់កូនអ្នកជាលើកទីមួយ ។*

*បើអ្នកមិនឆ្លើយតបនឹងសំណើឲ្យផ្តល់ការយល់ព្រមរបស់អ្នក ដើម្បីកូនអ្នកទទួលសេវាសិក្សាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀតជាលើកទីមួយនោះទេ, ឬបើអ្នកមិនព្រមផ្តល់ការយល់ព្រមនេះ រឺ ក្រោយបញ្ឈប់ការយល់ព្រមជាលាយលក្ខអក្សរ, មណ្ឌលអប់រំអ្នកប្រហែលជា មិនប្រើកិច្ចការពារតាមនីតិវិធី (គឺថា, ការ សម្រុះសម្រួល, បណ្តឹងត្រឹមត្រូវតាមច្បាប់, ការប្រជុំរកដំណោះស្រាយ, ឬសវនាការត្រឹមត្រូវតាមច្បាប់មិនលំអៀង) ដើម្បីទទួលបាននូវ ការយល់ស្របឬសេចក្តីសំរេចថា សេវាសិក្សាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀត (ផ្តល់អនុសាសន៍ដោយក្រុម IEP របស់កូនអ្នក) អាចត្រូវផ្តល់ដល់កូនអ្នកដោយគ្មានការយល់ព្រមរបស់អ្នក ។*

*បើអ្នកមិនព្រមផ្តល់ការយល់ព្រមរបស់អ្នកដើម្បីកូនអ្នកបានទទួល សេវាសិក្សាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀត ជាលើកទីមួយនោះទេ, ឬបើអ្នកមិនឆ្លើយតបចំពោះសំណើសុំឲ្យផ្តល់ការយល់ព្រមបែបនេះ រឺ ក្រោយបញ្ឈប់ការយល់ព្រមជាលាយលក្ខអក្សរ ហើយមណ្ឌលអប់រំ មិនផ្តល់សេវាសិក្សាអប់រំពិសេស និង សេវាទាក់ទិនដទៃទៀតដល់កូនអ្នក ដែលគេបានខិតខំស្វែងរកការយល់ព្រមរបស់អ្នក, នោះមណ្ឌលអប់រំអ្នក:*

1. *មិនរំលោភលក្ខខ័ណ្ឌតម្រូវឲ្យមានការអប់រំសាធារណៈដោយឥតគិតថ្លៃ (FAPE) សំរាប់កូនអ្នកដោយមកពីខ្លួនខកខានមិនបានផ្តល់សេវាទាំងនោះដល់កូនអ្នកឡើយ;* ***<u>ហើយ</u>***
2. *មិនតម្រូវឲ្យមានការប្រជុំអំពីកម្មវិធីអប់រំសំរាប់បុគ្គល (IEP) ឬបង្កើត IEP មួយសំរាប់កូនអ្នកសំរាប់សេវាសិក្សាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀត ដែលគេបានសុំការយល់ព្រមរបស់អ្នកដើម្បីធ្វើនោះឡើយ ។*

*បើអ្នកបញ្ឈប់នូវការយល់ព្រមជាលាយលក្ខអក្សរនៅពេលណាមួយបន្ទាប់ពីកូនអ្នកត្រូវបានផ្តល់នូវសេវាអប់រំពិសេស និង សេវាដែលទាន់ទិនដំបូង, ដូច្នេះ មណ្ឌលអប់រំប្រហែលជានឹងមិនបន្តរផ្តល់នូវការអប់រំពិសេស និង សេវាដែលទាន់ទិន, ប៉ុន្តែត្រូវជូនដំណឹងជាលាយលក្ខអក្សរ ដល់អ្នកជាមុន, ដូចដែលមានចែងនៅក្នុងសេចក្តីជូនដំណឹង, មុននឹងបញ្ឈប់សេវាទាំងនោះ។*

### *ការយល់ព្រមរបស់មាតាបិតា សំរាប់ការវាយតំលៃឡើងវិញ*

*មណ្ឌលអប់រំអ្នកត្រូវតែទទួលការយល់ព្រមរបស់អ្នក មុននឹងខ្លួនវាយតំលៃកូនអ្នកឡើងវិញ, លើកលែងតែមណ្ឌលអប់រំអ្នកអាចបង្ហាញថា:*

1. *ខ្លួនបានចាត់វិធានការសមស្របដើម្បីបានការយល់ព្រមពីអ្នកសំរាប់ការវាយតំលៃកូនអ្នកឡើងវិញ;* ***<u>ហើយ</u>***
2. *អ្នកមិនបានឆ្លើយតប ។*

*បើអ្នកបដិសេធមិនយល់ព្រមឲ្យមានការវាយតំលៃកូនអ្នកឡើងវិញទេ, មណ្ឌលអប់រំអាច, តែមិនតម្រូវឲ្យធ្វើនោះឡើយ, បន្តវាយតំលៃកូនអ្នកឡើងវិញ ដោយប្រើវិធីសម្រុះសម្រួល, បណ្តឹងត្រឹមត្រូវតាមច្បាប់, ប្រជុំរកដំណោះស្រាយ, និងសវនាការត្រឹមត្រូវតាមច្បាប់មិនលំអៀង ដើម្បីជំនះការបដិសេធរបស់អ្នកក្នុងការផ្តល់ការយល់ព្រមដើម្បីឲ្យមានការវាតំលៃកូនអ្នកឡើងវិញ ។ ដូចគ្នានឹងករណីការវាយតំលៃជាលើកដំបូងដែរ, មណ្ឌលអប់រំអ្នកមិនរំលោភលើកាតព្វកិច្ចរបស់ខ្លួន ក្រោមផ្នែក B នៃច្បាប់ IDEA ប្រសិនបើខ្លួនសំរេចបន្តការវាយតំលៃឡើងវិញ យ៉ាងដូច្នេះ ។*

### *កំណត់ត្រានៃការខិតខំប្រឹងប្រែងដ៏សមស្រប ដើម្បីទទួលបានការយល់ព្រមរបស់មាតាបិតា*

*សាលាអ្នកត្រូវតែរក្សាទុកនូវកំណត់ត្រានៃកិច្ចខិតខំប្រឹងប្រែងដ៏សមស្រប ដើម្បីទទួលបានការយល់ព្រមរបស់មាតាបិតា សំរាប់ការវាយតំលៃជាលើកដំបូង, ដើម្បីផ្តល់សេវាសិក្សាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀតជាលើកទីមួយ, ដើម្បីធ្វើការវាយតំលៃ, និង ដើម្បីរកមាតាបិតានៃកុមារដែលគេគ្រប់គ្រង សំរាប់ការវាយតំលៃជាលើកដំបូង ។ កំណត់ត្រានោះត្រូវតែមានឯកសារមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់មណ្ឌលអប់រំ ក្នុងផ្នែកទាំងនេះ, មានដូចជា:*

1. ឯកសារពិស្តារអំពីការហៅទូរស័ព្ទដែលបានធ្វើឡើងឬបានប៉ុនប៉ងធ្វើ និងលទ្ធផលនៃការហៅទូរស័ព្ទទាំងនោះ;
2. ច្បាប់ចំលងនៃលិខិតដែលបានផ្ញើទៅមាតាបិតា និងការឆ្លើយតបទាំងឡាយណាដែលបានទទួល; **ហើយនិង**
3. ឯកសារពិស្តារអំពីការទៅផ្ទះឬកន្លែងធ្វើការមាតាបិតា និងលទ្ធផលនៃដំណើរទាំងនោះ ។

***តម្រូវការការយល់ព្រមដទៃទៀត***

*ការយល់ព្រមរបស់អ្នកមិនតម្រូវឲ្យមានឡើយ មុនពេលមណ្ឌលអប់រំអ្នកអាច:*

1. *ពិនិត្យទិន្នន័យដែលមានស្រាប់ ជាចំណែកនៃការវាយតំលៃឬវាយតំលៃកូនអ្នកឡើងវិញ;* ***ឬ***
2. *ឲ្យកូនអ្នកធ្វើតេស្ត ឬការវាយតំលៃដទៃទៀត ដែលកុមារទាំងអស់ត្រូវធ្វើ លើកលែងតែ, មុនពេលធ្វើតេស្តឬការវាយតំលៃនោះ, ត្រូវមានការយល់ព្រមពីមាតាបិតានៃកុមារទាំងអស់ ។*

*មណ្ឌលអប់រំអ្នកមិនអាចប្រើការបដិសេធមិនផ្តល់ការយល់ព្រមទទួលសេវាកម្មឬសកម្មភាពមួយរបស់អ្នក ដើម្បីបដិសេធមិនផ្តល់សេវា, ផលប្រយោជន៍, ឬសកម្មភាពដទៃទៀតដល់អ្នក ឬកូនអ្នកឡើយ ។*

*បើអ្នកបានដាក់កូនអ្នកឲ្យរៀននៅសាលាឯកជនដោយចំណាយប្រាក់ផ្ទាល់ខ្លួន ឬបើអ្នកបង្រៀនកូនផ្ទាល់នៅផ្ទះ, ហើយអ្នកមិនផ្តល់ការយល់ព្រមរបស់អ្នកសំរាប់ការវាយតំលៃឬការវាយតំលៃកូនអ្នកឡើងវិញ, ឬអ្នកខកខានមិនបានឆ្លើយតបចំពោះសំណើសុំការយល់ព្រមរបស់អ្នកឲ្យផ្តល់ការយល់ព្រមរបស់អ្នក, មណ្ឌលអប់រំអ្នកមិនអាចប្រើនីតិវិធីសវនាការជំទាស់របស់ខ្លួន (គឺថា, ការសម្រុះសម្រួល, បណ្តឹងត្រឹមត្រូវតាមច្បាប់, ការប្រជុំរកដំណោះស្រាយ, ឬសវនាការត្រឹមត្រូវតាមច្បាប់មិនលំអៀង) និងមិនតម្រូវឲ្យយកកូនអ្នកទៅពិចារណាដើម្បីទទួលសេវាកម្មដែលមានសមធម៌ (សេវាកម្មដែលមានសំរាប់កុមារមានពិការភាព ដាក់ឲ្យរៀននៅសាលាឯកជនដោយមាតាបិតា) នោះឡើយ ។*

# *ការវាយតំលៃអប់រំឯករាជ្យ*

## 34 CFR §300.502

***ទូទៅ***

*ដូចរៀបរាប់ខាងក្រោម, អ្នកមានសិទ្ធិទទួលបានការវាយតំលៃអប់រំឯករាជ្យមួយ (IEE) នៃកូនអ្នក បើអ្នកមិនយល់ស្របនឹងការវាយតំលៃកូនអ្នកដែលមណ្ឌលអប់រំអ្នកទទួលបាន ។*

*បើអ្នកស្នើឲ្យមានការវាយតំលៃអប់រំឯករាជ្យមួយ, មណ្ឌលអប់រំអ្នកត្រូវតែផ្តល់ឲ្យអ្នកនូវពត៌មានអំពីទីកន្លែងដែលអ្នកអាចទទួលការវាយតំលៃអប់រំឯករាជ្យមួយ និងអំពីលក្ខណៈវិនិច្ឆ័យដែលអនុវត្តចំពោះការវាយតំលៃអប់រំឯករាជ្យ ។*

***និយមន័យ***

*ការវាយតំលៃអប់រំឯករាជ្យ មានន័យថា ការវាយតំលៃមួយធ្វើឡើងដោយអនុរក្សដែលមានសមត្ថភាពគ្រប់គ្រាន់ ដែលមិនបំរើការក្នុងមណ្ឌលអប់រំដែលជាអ្នកទទួលបន្ទុកផ្តល់ការសិក្សាអប់រំដល់កូនអ្នក ។*

*ចំណាយសាធារណៈ: មានន័យថា មណ្ឌលអប់រំជាអ្នកចេញថ្លៃការវាយតំលៃទាំងមូល ឬជាអ្នកធានាថាការវាយតំលៃនោះគឺផ្តល់ដល់អ្នកដោយឥតគិតថ្លៃ, គឺស្របទៅនឹងមាត្រានៃផ្នែក B នៃច្បាប់ IDEA, ដែលអនុញ្ញាតឲ្យរដ្ឋនីមួយៗប្រើធនធានឧបត្ថម្ភរបស់រដ្ឋ, មូលដ្ឋាន, សហព័ន្ធ និងឯកជន ដែលមានក្នុងរដ្ឋ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់ផ្នែក B នៃច្បាប់ ។*

***សិទ្ធិរបស់មាតាបិតាក្នុងការទទួលការវាយតំលៃ ដោយចំណាយសាធារណៈ:***

*អ្នកមានសិទ្ធិទទួលការវាយតំលៃអប់រំឯករាជ្យសំរាប់កូនអ្នកដោយចំណាយសាធារណៈ បើអ្នកមិនយល់ស្របនឹងការវាយតំលៃកូនអ្នកដែលមណ្ឌលអប់រំទទួលបាន; ដោយផ្អែកលើលក្ខខ័ណ្ឌដូចតទៅ:*

1. *បើអ្នកស្នើសុំឲ្យមានការវាយតំលៃអប់រំឯករាជ្យមួយសំរាប់កូនអ្នកដោយចំណាយសាធារណៈ, មណ្ឌលអប់រំអ្នកត្រូវតែ, ដោយគ្មានការពន្យារពេលមិនចាំបាច់,* **__ឬមួយ__**: (a) *ដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ដើម្បីស្នើសុំឲ្យមានសវនាការដើម្បីបង្ហាញថាការវាយតំលៃរបស់ខ្លួនលើកូនអ្នកគឺសមស្រប;* **__ឬ__** (b) *ផ្តល់ការវាយតំលៃអប់រំឯករាជ្យមួយដោយចំណាយសាធារណៈ, លើកលែងតែមណ្ឌលអប់រំបង្ហាញក្នុងសវនាការថា ការវាយតំលៃកូនអ្នកដែលអ្នកបានទទួល មិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់មណ្ឌលអប់រំ ។*
2. *បើអ្នកស្នើសុំឲ្យមានសវនាការមួយ ហើយសេចក្តីសំរេចចុងក្រោយគឺថា ការវាយតំលៃកូនអ្នករបស់មណ្ឌលអប់រំអ្នកគឺសមរម្យ, អ្នកនៅតែមានមានសិទ្ធិទទួលការវាយតំលៃអប់ឯករាជ្យមួយដដែល, ប៉ុន្តែមិនស្ថិតក្នុងចំណាយសាធារណៈឡើយ ។*
3. *បើអ្នកស្នើសុំឲ្យមានការវាយតំលៃអប់រំឯករាជ្យមួយសំរាប់កូនអ្នក, មណ្ឌលអប់រំអាចចោទសួរហេតុអ្វីបានជាអ្នកទាត់ចោលការវាយតំលៃកូនអ្នកទទួលបានដោយមណ្ឌលអប់រំអ្នក ។ ប៉ុន្តែ, មណ្ឌលអប់រំអ្នកមិនអាចតម្រូវឲ្យមានការការបកស្រាយមួយ ហើយមិនអាចពន្យារដោយមិនសមហេតុផល ក្នុងការផ្តល់ការវាយតំលៃអប់រំឯករាជ្យមួលសំរាប់កូនអ្នកដោយចំណាយសាធារណៈ ឬដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ដើម្បីស្នើសុំឲ្យមានសវនការត្រឹមត្រូវតាមច្បាប់ ដើម្បីការពារការវាយតំលៃកូនអ្នករបស់មណ្ឌលអប់រំ ។*

*អ្នកមានសិទ្ធិទទួលការវាយតំលៃអប់រំឯករាជ្យសំរាប់កូនអ្នកដោយចំណាយសាធារណៈតែម្តងប៉ុណ្ណោះ  រាល់ពេលដែលមណ្ឌលអប់រំអ្នកធ្វើការវាយតំលៃកូនអ្នក ដែលអ្នកមិនយល់ស្រប ។*

### ការវាយតំលៃផ្តើមគំនិតដោយមាតាបិតា

*បើអ្នកទទួលបានការវាយតំលៃអប់រំឯករាជ្យសំរាប់កូនអ្នកដោយចំណាយសាធារណៈ ឬអ្នកឲ្យមណ្ឌលអប់រំនូវការវាយតំលៃកូនអ្នកដែលអ្នកទទួលបានដោយចំណាយផ្ទាល់ខ្លួនៈ*

1. *មណ្ឌលអប់រំអ្នកត្រូវតែពិចារណាលទ្ធផលនៃការវាយតំលៃកូនអ្នកនោះ, ប្រសិនបើវាឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់មណ្ឌលអប់រំ សំរាប់ការវាយតំលៃអប់រំឯករាជ្យ, ក្នុងសេចក្តីសំរេចណាមួយដែលធ្វើឡើងដោយគោរពតាមមាត្រានៃច្បាប់ការសិក្សាអប់រំសាធារណៈសមរម្យដោយឥតគិតថ្លៃ* (FAPE) *ចំពោះកូនអ្នក;* **__ហើយ__**
2. *អ្នក ឬមណ្ឌលអប់រំអ្នកអាចបង្ហាញការវាយតំលៃនោះ ជាភស្តុតាងនៅឯសវនាការត្រឹមត្រូវតាមច្បាប់ ស្តីអំពីកូនអ្នក ។*

### សំណើឲ្យមានការវាយតំលៃដោយមន្ត្រីសវនាការ

*បើមន្ត្រីសវនាការម្នាក់ស្នើសុំឲ្យមានការវាយតំលៃអប់រំឯករាជ្យសំរាប់កូនអ្នក ជាផ្នែកមួយនៃសវនាការត្រឹមត្រូវតាមច្បាប់, នោះចំណាយនៃការវាយតំលៃនោះត្រូវតែជាចំណាយសាធារណៈ ។*

### លក្ខណៈវិនិច្ឆ័យរបស់មណ្ឌលអប់រំ

*បើការវាយតំលៃអប់រំឯករាជ្យមួយជាចំណាយសាធារណៈ, លក្ខណៈវិនិច្ឆ័យដែលការវាយតំលៃនោះត្រូវទទួលបាន, រួមទាំងទីកន្លែងនៃការវាយតំលៃនិងសមត្ថភាពនៃអ្នកវាយតំលៃផង, ត្រូវតែដូចគ្នានឹងលក្ខណៈវិនិច្ឆ័យដែលមណ្ឌលអប់រំប្រើពេលខ្លួនផ្តើមឲ្យមានការវាយតំលៃមួយឡើយដូចេ្នាះដែរ (ឲ្យបានដល់កម្រិតដែលលក្ខណៈវិនិច្ឆ័យទាំងនោះស្របទៅតាមសិទ្ធិរបស់អ្នកក្នុងការទទួលការវាយតំលៃអប់រំឯករាជ្យមួយ) ។*

*លើកលែងតែចំពោះលក្ខណៈវិនិច្ឆ័យដែលបានរៀបរាប់ខាងលើ, មណ្ឌលអប់រំមួយមិនអាចដាក់លក្ខខ័ណ្ឌឬកំណត់ពេលវេលា ទាក់ទងនឹងការធ្វើការវាយតំលៃអប់រំឯករាជ្យដោយចំណាយសាធារណៈឡើយ ។*

# ការរក្សាការសម្ងាត់នៃពត៌មាន

## និយមន័យ

### 34 CFR §300.611

*ដូចប្រើក្នុងជំពូក* ***ការរក្សាការសម្ងាត់នៃពត៌មាន:***

- *ការបំផ្លាញចោល* មានន័យថា ការបំផ្លាញចោលជាក់ស្តែង ឬការដកចេញពត៌មានសំគាល់ខ្លួនបុគ្គលពីពត៌មាន ដើម្បីឲ្យពត៌មាននោះមិនអាចសំគាល់អត្តសញ្ញាណបុគ្គលតទៅទៀតបាន ។
- *ឯកសារអប់រំ* មានន័យថា ជាប្រភេទឯកសារមានចែងក្នុងនិយមន័យ "ឯកសារអប់រំ" ក្នុងជំពូក 34 CFR ផ្នែក 99 (មាត្រាអនុវត្ត ច្បាប់ស្តីពីសិទ្ធិសិក្សាអប់រំគ្រួសារ និងភាពជាឯកជន ឆ្នាំ 1974, 20 U.S.C. 1232g (FERPA)) ។
- *ទីភ្នាក់ងារចូលរួម* មានន័យថា មណ្ឌលអប់រំ, ទីភ្នាក់ងារ ឬស្ថាប័នណាមួយ ដែលប្រមូលយក, រក្សាទុក, ឬប្រើប្រាស់ពត៌មានដែលអាចសំគាល់អត្តសញ្ញាណបុគ្គលបាន, ឬដែលគេអាចយកពត៌មានពីទីនោះបាន, ក្រោមផ្នែក B នៃច្បាប់ IDEA ។

## ពត៌មានដែលអាចសំគាល់អត្តសញ្ញាណបុគ្គលបាន

### 34 CFR §300.32

*ពត៌មានដែលអាចសំគាល់អត្តសញ្ញាណបុគ្គលបាន* មានន័យថា ជាពត៌មានដែលមាន:

(a) ឈ្មោះកូនអ្នក, ឈ្មោះអ្នកដែលជាមាតាបិតា, ឬឈ្មោះសមាជិកគ្រួសារណាម្នាក់ទៀត;
(b) អាសយដ្ឋានរបស់កូនអ្នក;
(c) ពត៌មានសំគាល់បុគ្គលផ្ទាល់ខ្លួន, ដូចជា លេខសូសូហ្សាល់ឬអត្តលេខសិស្សរបស់កូនអ្នក; **ឬ**
(d) បញ្ជីរាយលក្ខណៈកិនភាគផ្ទាល់ខ្លួន ឬពត៌មានដទៃទៀត ដែលធ្វើឲ្យមានលទ្ធភាពសំគាល់កូនអ្នក ដោយភាពច្បាស់លាស់គួរសម ។

## សេចក្តីជូនដំណឹងចំពោះមាតាបិតា

### 34 CFR §300.612

ទីភ្នាក់ងារអប់រំរដ្ឋត្រូវតែឲ្យសេចក្តីជូនដំណឹងគ្រប់គ្រាន់ ដើម្បីជំរាបជូនមាតាបិតាឲ្យបានពេញលេញ អំពីការរក្សាការសម្ងាត់នៃពត៌មានដែលសំគាល់អត្តសញ្ញាណបុគ្គលបាន, រួមមាន:

1. ការពិពណ៌នាអំពីវិសាលភាពដែលសេចក្តីជូនដំណឹងនេះត្រូវផ្តល់ឲ្យ ជាភាសាកំណើតរបស់សហគមន៍ពលរដ្ឋនានាក្នុងរដ្ឋ;
2. ការពិពណ៌នាអំពីកុមារ ដែលពត៌មានដែលអាចសំគាល់អត្តសញ្ញាណបុគ្គលរបស់គេ ត្រូវបានរក្សាទុក, ប្រភេទពត៌មានដែលចង់បាន, វិធីសាស្ត្រដែលរដ្ឋមានបំណងប្រើប្រាស់ក្នុងការប្រមូលពត៌មាននោះ (រួមទាំងប្រភពដែលពត៌មានត្រូវគេប្រមូលយក ផង), និងការប្រើប្រាស់នានានៃពត៌មានដែលនឹងកើតមាន;
3. សេចក្តីសង្ខេបនៃគោលការណ៍និងនីតិវិធីនានា ដែលទីភ្នាក់ងារចូលរួមត្រូវតែអនុវត្តតាម ទាក់ទងនឹងការស្តុកទុក, ការបង្ហាញទៅភាគីទីបី, ការរក្សាទុក, និងការបំផ្លាញចោលពត៌មានដែលអាចសំគាល់អត្តសញ្ញាណបុគ្គលបាន; **និង**
4. ការពិពណ៌នាអំពីសិទ្ធិទាំងអស់របស់មាតាបិតានិងកុមារ ទាក់ទងនឹងពត៌មាននេះ, រួមទាំងសិទ្ធិក្រោមច្បាប់ស្តីពីសិទ្ធិការសិក្សាអប់រំគ្រួសារនិងភាពជាឯកជន (FERPA) និងមាត្រាអនុវត្តរបស់វា ក្នុងជំពូក 34 CFR ផ្នែក 99 ។

*មុនពេលសកម្មភាពចម្បងណាមួយដើម្បីកំណត់អត្តសញ្ញាណ, ទីតាំង, ឬវាយតំលៃ កុមារដែលត្រូវការ នូវសេវាអប់រំពិសេសនិងសេវាទាក់ទិន (ដែលត្រូវគេស្គាល់ថា "ស្វែងរកកុមារ"), សេចក្តីជូនដំណឹងនោះត្រូវតែបោះពុម្ពនិងផ្សព្វផ្សាយក្នុងកាសែតឬសារពត៌មានដទៃទៀត, ឬទាំងពីរ, ដែលមានការចែកចាយគ្រប់គ្រាន់ ដើម្បីជូន ដំណឹងដល់មាតាបិតាទូទាំងរដ្ឋ នៃសកម្មភាពទាំងនេះ ។*

# *សិទ្ធិក្នុងការចូលពិនិត្យ*

## 34 CFR §300.613

*ទីភ្នាក់ងារចូលរួមត្រូវតែអនុញ្ញាតឲ្យអ្នកពិនិត្យនិងពិនិត្យដោយហ្មត់ចត់ឡើងវិញនូវឯកសារអប់រំណាក៏ដោយដែលទាក់ទងនឹងកូនអ្នក ដែលត្រូវគេប្រមូលបាន, រក្សាទុក, ឬប្រើប្រាស់ដោយមណ្ឌលអប់រំអ្នក ក្រោមផ្នែក* B *នៃច្បាប់* IDEA *។ ទីភ្នាក់ងារចូលរួមត្រូវតែធ្វើតាមសំណើរបស់អ្នកសុំពិនិត្យនិងពិនិត្យដោយហ្មត់ចត់ឡើងវិញឯកសារអប់រំអំពីកូនអ្នកណាមួយក៏ដោយ ដោយគ្មានការពន្យារពេលមិនចាំបាច់ និងមុនពេលការប្រជុំណាមួយទាក់ទងនឹងកម្មវិធីអប់រំសំរាប់បុគ្គល*(IEP)*, ឬសវនាការត្រឹមត្រូវតាមច្បាប់ណាមួយ (រួមទាំងការជួបប្រជុំរកដំណោះស្រាយ ឬសវនាការរឿងវិន័យណាមួយ), ហើយទោះក្នុងករណីណាក៏ដោយ មិនឲ្យលើសពី៤៥ថ្ងៃប្រក្រតិទិន បន្ទាប់ពីអ្នកបានធ្វើការស្នើសុំ ។*

*សិទ្ធិរបស់អ្នកក្នុងការពិនិត្យនិងពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញ រួមមាន:*

1. *សិទ្ធិរបស់អ្នកក្នុងការទទួលការឆ្លើយតបពីទីភ្នាក់ងារចូលរួម ចំពោះសំណើសមហេតុផលរបស់អ្នក សុំឲ្យមានការពន្យល់និងបកស្រាយឯកសារ;*
2. *សិទ្ធិរបស់អ្នកក្នុងការស្នើសុំឲ្យទីភ្នាក់ងារចូលរួមផ្តល់នូវច្បាប់ចំឡងនៃឯកសារ បើអ្នកមិនអាចពិនិត្យនិងពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញបានដោយមានប្រសិទ្ធិភាព លុះត្រាតែអ្នកបានទទួលច្បាប់ចំឡងទាំងនោះ;* ***និង***
3. *សិទ្ធិរបស់អ្នកក្នុងការឲ្យអ្នកតំណាងរបស់អ្នកពិនិត្យនិងពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញនូវឯកសារនោះ ។*

*ទីភ្នាក់ងារចូលរួមអាចសន្មត់ថាអ្នកមានអំណាចពិនិត្យនិងពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញនូវឯកសារទាក់ទងនឹងកូនអ្នក លើកលែងតែគេបានដំណឹងថាអ្នកមិនមានអំណាចឡើយក្រោមច្បាប់រដ្ឋដែលមានសុពលភាព ស្តីពីបញ្ហាដូចជា សិទ្ធិជាអាណាព្យាបាលស្របច្បាប់, ឬការបែកផ្លូវគ្នានិងការលែងលះ ។*

# *កំណត់ត្រានៃការចូលពិនិត្យ*

## 34 CFR §300.614

*ទីភ្នាក់ងារចូលរួមនីមួយៗត្រូវតែរក្សាទុកនូវកំណត់ត្រានៃភាគីនានា ដែលបានទទួលឲ្យចូលពិនិត្យឯកសារអប់រំដែលបានប្រមូល, រក្សាទុក, ឬបានប្រើប្រាស់ ក្រោមផ្នែក* B *នៃច្បាប់* IDEA *(លើកលែងតែការចូលពិនិត្យដោយមាតាបិតានិងបុគ្គលិកដែលមានការអនុញ្ញាតនៃទីភ្នាក់ងារចូលរួម), ដោយកត់ត្រាទុកនូវឈ្មោះនៃភាគី, កាលបរិច្ឆេទឲ្យចូល, និងកម្មវត្ថុដែលភាគីនោះត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារ ។*

# *ឯកសារអំពីកុមារលើសពីម្នាក់*

## 34 CFR §300.615

*ប្រសិនបើឯកសារអប់រំណាមួយមានពត៌មានអំពីកុមារលើសពីម្នាក់, មាតាបិតានៃកុមារទាំងនោះមានសិទ្ធិពិនិត្យនិងពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញ តែពត៌មានណាដែលទាក់ទិននឹងកូនរបស់ខ្លួន ឬត្រូវជូនដំណឹងអំពីពត៌មានជាក់លាក់នោះ ។*

# បញ្ជីប្រភេទនិងទីកន្លែងនៃពត៌មាន

## 34 CFR §300.616

*តាមការស្នើសុំ, ទីភ្នាក់ងារចូលរួមនីមួយៗត្រូវតែផ្ដល់ដល់អ្នកនូវបញ្ជីមួយមានរាយប្រភេទនិងទីកន្លែងនៃឯកសារអប់រំ ដែលបានប្រមូល, រក្សាទុក, ឬប្រើប្រាស់ដោយទីភ្នាក់ងារនោះ ។*

# ការបង់ប្រាក់

## 34 CFR §300.617

*ទីភ្នាក់ងារចូលរួមនីមួយៗអាចតម្រូវឲ្យបង់ប្រាក់សំរាប់ថតចំឡងឯកសារដែលគេបានធ្វើសំរាប់អ្នក ក្រោមផ្នែក B នៃច្បាប់* IDEA, *បើសិនជាការបង់ប្រាក់នោះមិនរារាំងអ្នកពីការប្រើសិទ្ធិរបស់អ្នកក្នុងការពិនិត្យនិងពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញនូវឯកសារទាំងនោះទេ ។*

*ទីភ្នាក់ងារចូលរួមមួយមិនអាចតម្រូវឲ្យអ្នកបង់ប្រាក់សំរាប់ការរាវរក ឬរកបានមកនូវពត៌មាន ក្រោមផ្នែក* B *នៃច្បាប់* IDEA *ឡើយ ។*

# ការកែប្រែឯកសារតាមសំណើមាតាបិតា

## 34 CFR §300.618

*ប្រសិនបើអ្នកជឿជាក់ថា ពត៌មាននៅក្នុងឯកសារអប់រំទាក់ទងនឹងកូនអ្នក ដែលត្រូវគេប្រមូលមក, រក្សាទុក, ឬប្រើប្រាស់ក្រោមផ្នែក* B *នៃច្បាប់* IDEA *មិនត្រឹមត្រូវ, នាំឲ្យយល់ខុស, ឬរំលោភសិទ្ធិជាឯកជនឬសិទ្ធិផ្សេងទៀតរបស់កូនអ្នក, នោះអ្នកអាចស្នើសុំឲ្យទីភ្នាក់ងារចូលរួមដែលជាអ្នករក្សាពត៌មាននោះ កែប្រែពត៌មាននោះបាន ។*

*ទីភ្នាក់ងារចូលរួមនោះ ត្រូវតែសំរេចថាតើត្រូវកែប្រែពត៌មាននោះតាមសំណើរបស់អ្នក ក្នុងរយៈពេលមួយសមរម្យ បន្ទាប់ពីបានទទួលសំណើអ្នក ។*

*ប្រសិនបើទីភ្នាក់ងារចូលរួមនោះមិនព្រមកែប្រែពត៌មាននោះតាមសំណើអ្នកទេ, ខ្លួនត្រូវជូនដំណឹងដល់អ្នកអំពីការបដិសេធនោះ ហើយប្រាប់អ្នកអំពីសិទ្ធិឲ្យមានសវនាការសំរាប់គោលបំណងនេះ ដូចដែលបានរៀបរាប់ក្នុងជំពូក ឱកាសមានសវនាការ ។*

# ឱកាសមានសវនាការ

## 34 CFR §300.619

*ទីភ្នាក់ងារចូលរួមនោះត្រូវតែ, តាមសំណើ, ផ្ដល់ដល់អ្នកនូវឱកាសមានសវនាការមួយ ដើម្បីតវ៉ាពត៌មានក្នុងឯកសារអប់រំទាក់ទងនឹងកូនអ្នក ដើម្បីបញ្ជាក់ថាវាមិនមែនមិនត្រឹមត្រូវ, មិនធ្វើឲ្យយល់ខុស, ឬក៏រំលោភសិទ្ធិជាឯកជនឬសិទ្ធិដទៃទៀតរបស់កូនអ្នកឡើយ ។*

# នីតិវិធីសវនាការ

## 34 CFR §300.621

*សវនាការមួយដើម្បីតវ៉ាពត៌មានក្នុងឯកសារអប់រំ ត្រូវតែធ្វើឡើងតាមនីតិវិធីសំរាប់សវនាការបែបនេះ ក្រោមច្បាប់ស្ដីពីសិទ្ធិការសិក្សាអប់រំគ្រួសារនិងភាពជាឯកជន* (FERPA) *។*

# លទ្ធផលនៃសវនាការ

## 34 CFR §300.620

*ប្រសិនបើ, ជាលទ្ធផលនៃសវនាការ, ទីភ្នាក់ងារចូលរួមនោះសំរេចថា ពត៌មាននោះមិនត្រឹមត្រូវ, ធ្វើឲ្យយល់ខុសឬក៏រំលោភសិទ្ធិជាឯកជនឬសិទ្ធិដទៃទៀតរបស់កុមារ, ខ្លួនត្រូវតែកែប្រែពត៌មាននោះឲ្យបានសមស្រប និងឲ្យដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ ។*

*ប្រសិនបើ, ជាលទ្ធផលនៃសវនាការ, ទីភ្នាក់ងារចូលរួមនោះសំរេចថា ពត៌មាននោះមិនមែនមិនត្រឹមត្រូវ, មិនមែនធ្វើឲ្យយល់ខុស ឬក៏ រំលោភសិទ្ធិជាឯកជន ឬសិទ្ធិដទៃទៀតរបស់កុមារទេ, ខ្លួនត្រូវតែឲ្យដំណឹងដល់អ្នកអំពីសិទ្ធិរបស់អ្នក ក្នុងការដាក់នៅក្នុងឯកសារដែលខ្លួន រក្សាទុកអំពីកូនរបស់អ្នកនោះ នូវសេចក្តីអះអាងមួយឲ្យជាយោបល់ចំពោះពត៌មាននោះ ឬផ្តល់ហេតុផលណាដែលធ្វើឲ្យអ្នកមិនយល់ស្រប នឹងសេចក្តីសំរេចរបស់ទីភ្នាក់ងារចូលរួមនោះ ។*

*ការពន្យល់បែបនេះ ដាក់ក្នុងឯកសារកូនអ្នក ត្រូវតែ:*

1. *រក្សាទុកដោយទីភ្នាក់ងារចូលរួមនោះ ជាផ្នែកមួយនៃឯកសាររបស់កូនអ្នក ដរាបណាឯកសារឬផ្នែកដែលមានការតវ៉ានោះនៅតែ ត្រូវរក្សាទុកដោយទីភ្នាក់ងារចូលរួមនោះ;* ***និង***
2. *ប្រសិនបើទីភ្នាក់ងារចូលរួមនោះបញ្ចេញឯកសាររបស់កូនអ្នក ឬផ្នែកដែលមានការតវ៉ានោះ ទៅឲ្យភាគីណាក៏ដោយ, ការពន្យល់ នោះត្រូវតែបង្ហាញទៅភាគីនោះដែរ ។*

# ការយល់ព្រមឲ្យបញ្ចេញពត៌មានដែលអាចសំគាល់បុគ្គលបាន

## 34 CFR §300.622

*លើកលែងតែពត៌មាននោះមាននៅក្នុងឯកសារអប់រំ, ហើយការបញ្ចេញនោះបានត្រូវអនុញ្ញាតដោយគ្មានការយល់ព្រមរបស់មាតាបិតា ក្រោមច្បាប់ស្តីពីសិទ្ធិការសិក្សាអប់រំគ្រួសារនិងភាពជាឯកជន (FERPA), ការយល់ព្រមរបស់អ្នកត្រូវតែត្រូវទទួលបាន មុនពេល ពត៌មានដែលអាចសំគាល់បុគ្គលបាននោះត្រូវគេបញ្ចេញទៅឲ្យភាគីនានា ក្រៅពីមន្ត្រីរបស់ទីភ្នាក់ងារចូលរួម ។ លើកលែងតែក្នុង កាលៈទេសៈដូចបញ្ជាក់ខាងក្រោមនេះ, ការយល់ព្រមរបស់អ្នកមិនចាំបាច់មានឡើយ នៅមុនពេលពត៌មានដែលអាចសំគាល់បុគ្គលបាន ត្រូវគេបញ្ចេញទៅឲ្យមន្ត្រីរបស់ទីភ្នាក់ងារចូលរួម ក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការនៃផ្នែក B នៃច្បាប់ IDEA*

*ការយល់ព្រមរបស់អ្នក, ឬការយល់ព្រមរបស់កូនដែលដល់អាយុនីតិភាពក្រោមច្បាប់រដ្ឋ, ត្រូវតែបានទទួល មុនពេលពត៌មានដែលអាច សំគាល់បុគ្គលបាន ត្រូវបញ្ចេញទៅឲ្យមន្ត្រីរបស់ទីភ្នាក់ងារចូលរួមនានាដែលជាអ្នកផ្តល់ឲ្យឬបង់កំរៃសំរាប់សេវាអន្តរកាលនានា ។*

*ប្រសិនបើកូនអ្នកកំពុងរៀននៅ, ឬនឹងទៅរៀននៅ, សាលាឯកជនដែលមិនស្ថិតនៅក្នុងមណ្ឌលអប់រំដែលអ្នករស់នៅ, ការយល់ព្រមរបស់ អ្នកត្រូវតែទទួលបាន មុនពេលពត៌មានដែលអាចសំគាល់បុគ្គលបានអំពីកូនអ្នក ត្រូវបញ្ចេញឲ្យរវាងមន្ត្រីក្នុងមណ្ឌលអប់រំដែលសាលា ឯកជននោះស្ថិតនៅនិងមន្ត្រីក្នុងមណ្ឌលអប់រំដែលអ្នករស់នៅ ។*

# កិច្ចការពារ

## 34 CFR §300.623

*ទីភ្នាក់ងារចូលរួមនីមួយៗត្រូវតែការពារភាពសម្ងាត់នៃពត៌មានដែលអាចសំគាល់បុគ្គលបាន នៅដំណាក់កាលប្រមូល, ស្តុកទុក, បញ្ចេញ, និងបំផ្លាញចោល ។*

*មន្ត្រីម្នាក់ក្នុងទីភ្នាក់ងារចូលរួមនីមួយៗ ត្រូវតែទទួលខុសត្រូវក្នុងការធានាការសម្ងាត់នៃពត៌មានដែលអាចសំគាល់បុគ្គលបានទាំងអស់ ។*

*បុគ្គលទាំងអស់ដែលប្រមូល ឬប្រើប្រាស់ពត៌មានដែលអាចសំគាល់បុគ្គលបាន ត្រូវតែទទួលការបណ្តុះបណ្តាលឬការណែនាំ ទាក់ទងនឹង គោលការណ៍និងនីតិវិធីរបស់រដ្ឋអ្នក ទាក់ទងនឹងការរក្សាការសម្ងាត់ ក្រោមផ្នែក B នៃច្បាប់ IDEA និងច្បាប់ស្តីពីសិទ្ធិសិក្សាអប់រំគ្រួសារ និងភាពជាឯកជន (FERPA) ។*

*ទីភ្នាក់ងារចូលរួមនីមួយៗត្រូវតែរក្សាទុក, សំរាប់ការត្រួតពិនិត្យសាធារណៈ, បញ្ជីរាយនាមនិងមុខនាទីថ្មីមួយ នៃបុគ្គលិកក្នុងទីភ្នាក់ងារនោះ ដែលអាចចូលមើលពត៌មានដែលអាចសំគាល់បុគ្គលបាន ។*

## ការបំផ្លាញចោលពត៌មាន

### 34 CFR §300.624

*មណ្ឌលអប់រំអ្នកត្រូវតែជំរាបអ្នកនៅពេលដែលពត៌មានដែលអាចសំគាល់បុគ្គលបានដែលបានត្រូវប្រមូល, រក្សាទុក, ឬប្រើប្រាស់ មិនត្រូវការទៀតឡើយ ក្នុងការផ្តល់សេវាអប់រំដល់កូនអ្នក ។*

*ពត៌មាននោះត្រូវតែបំផ្លាញចោលតាមសំណើរបស់អ្នក ។ ប៉ុន្តែ, ឯកសារអចិន្ត្រៃមួយដែលមានឈ្មោះ, អាសយដ្ឋាន, និងលេខទូរស័ព្ទរបស់កូនអ្នក, ពិន្ទុ, វត្តមាន, ថ្នាក់ដែលបានរៀន, កម្រិតថ្នាក់ដែលបានបញ្ចប់, និងឆ្នាំបញ្ចប់របស់វា អាចត្រូវរក្សាទុក ដោយគ្មានពេលកំណត់ ។*

# នីតិវិធីបណ្តឹងរដ្ឋ

## ភាពខុសគ្នារវាងបណ្តឹងត្រឹមត្រូវតាមច្បាប់ និងនីតិវិធីបណ្តឹងរដ្ឋ

*បទបញ្ញត្តសំរាប់ផ្នែក B នៃច្បាប់ IDEA ដាក់ចេញនូវនីតិវិធីដាច់ដោយឡែកពីគ្នា សំរាប់បណ្តឹងរដ្ឋ និងសំរាប់បណ្តឹងនិងសវនាការត្រឹមត្រូវតាមច្បាប់ ។ ដូចដែលបកស្រាយខាងក្រោម, បុគ្គលណាម្នាក់ឬអង្គការណាមួយ អាចដាក់បណ្តឹងរដ្ឋចោទប្រកាន់ការរំលោភមាត្រាណាមួយនៃផ្នែក B ដោយមណ្ឌលអប់រំ, ទីភ្នាក់ងារអប់រំរដ្ឋ, ឬទីភ្នាក់ងារសាធារណៈដទៃទៀត ។ មានតែអ្នក ឬមណ្ឌលអប់រំណាមួយប៉ុណ្ណោះ ដែលអាចដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់លើបញ្ហាណាមួយដែលជាប់ទាក់ទិននឹងសំណើឬការបដិសេធមិនផ្តើមឲ្យមានឬកែប្រែអត្តសញ្ញាណកម្ម, ការវាយតំលៃឬការរកគ្រឹះស្ថានសិក្សាឲ្យកុមារដែលមានពិការភាព, ឬការផ្តល់ការសិក្សាអប់រំសាធារណៈសមរម្យដោយឥតគិតថ្លៃ (FAPE) ដល់កុមារនោះ ។ ក្នុងខណៈដែលបុគ្គលិកទីភ្នាក់ងារអប់រំរដ្ឋត្រូវតែដោះស្រាយបណ្តឹងរដ្ឋឲ្យបានក្នុងរយៈពេល 60 ថ្ងៃប្រក្រតិទិន, លើកលែងតែរយៈពេលនោះត្រូវគេពន្យារដោយត្រឹមត្រូវ, មន្ត្រីសវនាការត្រឹមត្រូវតាមច្បាប់មិនលំអៀង ត្រូវតែដោះស្រាយបណ្តឹងត្រឹមត្រូវតាមច្បាប់ (ប្រសិនបើវាមិនត្រូវបានដោះស្រាយដោយអង្គប្រជុំដើម្បីរកដំណោះស្រាយ ឬតាមរយៈការសម្រុះសម្រួលទេ) ហើយត្រូវចេញសេចក្តីសំរេចជាលាយលក្ខណ៍អក្សរមួយ ក្នុងរយៈពេល45 ថ្ងៃប្រក្រតិទិន ក្រោយពីចុងបញ្ចប់នៃរយៈពេលដោះស្រាយ, ដូចដែលរៀបរាប់ក្នុងឯកសារនេះ ក្រោមជំពូក ដំណើរការនៃការដោះស្រាយ, លើកលែងតែមន្ត្រីសវនាការ ផ្តល់ឲ្យមានការពន្យារពេលជាក់លាក់ណាមួយតាមសំណើរបស់អ្នក ឬតាមសំណើរបស់មណ្ឌលអប់រំ ។ បណ្តឹងរដ្ឋនិងបណ្តឹងត្រឹមត្រូវតាមច្បាប់, នីតិវិធីរកដំណោះស្រាយនិងសវនាការ នឹងត្រូវរៀបរាប់កាន់តែពេញលេញជាងនេះទៀតនៅផ្នែកខាងក្រោមនេះ ។*
*ភ្នាក់ងារអប់រំរដ្ឋត្រូវបង្កើតនូវទំរង់គំរូដើម្បីជួយអ្នកធ្វើរ បណ្តឹងត្រឹមត្រូវតាមច្បាប់ និង ជួយអ្នក រឺ បុគ្គលដ៏ទៃធ្វើបណ្តឹងរដ្ឋដូចដែលរៀបរាប់នៅក្រោមជំពូក* ***ទំរង់គំរូ***។

## ការអនុវត្តន៏នីតិវិធីបណ្តឹងរដ្ឋ

### 34 CFR §300.151

***ទូទៅ***

*ទីភ្នាក់ងារអប់រំរដ្ឋនិមួយៗត្រូវតែមាននីតិវិធីជាលាយលក្ខណ៍អក្សរ សំរាប់:*

1. *ដោះស្រាយបណ្តឹងណាមួយ, រួមទាំងបណ្តឹងដាក់ដោយអង្គការឬបុគ្គលណាម្នាក់ពីរដ្ឋដទៃ;*
2. *ការដាក់បណ្តឹងទៅទីភ្នាក់ងារអប់រំរដ្ឋ;*
3. *ចែកផ្សាយឲ្យបានទូលំទូលាយ នូវនីតិវិធីបណ្តឹង ឲ្យដល់មាតាបិតានិងបុគ្គលដែលមានការចាប់អារម្មណ៍ដទៃទៀត, រួមទាំងមជ្ឈមណ្ឌលពត៌មាននិងបណ្តុះបណ្តាលមាតាបិតា, ទីភ្នាក់ងារខាងការគាំទ្រនិងការពារនានា, មជ្ឈមណ្ឌលរស់នៅដោយឯករាជ្យនានា, និងស្ថាប័នសមស្របដទៃទៀត ។*

### *ដំណោះស្រាយសំរាប់ការបដិសេធសេវាសមស្របនានា*

*ក្នុងការដោះស្រាយបណ្តឹងរដ្ឋមួយ ដែលក្នុងនោះទីភ្នាក់ងារអប់រំរដ្ឋបានរកឃើញការខកខានមិនបានផ្តល់សេវាសមស្របនានា, ទីភ្នាក់ងារអប់រំរដ្ឋ ត្រូវតែដោះស្រាយ:*

1. *ការខកខានមិនបានផ្តល់សេវាសមស្របទាំងនោះ, រួមទាំងវិធានការកែតម្រូវសមស្របដើម្បីឆ្លើយតបនឹងតម្រូវការរបស់កុមារ; (ដូចជា សេវាសំណង ឬ លុយសំណង)* ***និង***
2. *ការផ្តល់សេវាសមស្របនាពេលអនាគត់ សំរាប់កុមារទាំងអស់ដែលមានពិការភាព ។*

# *នីតិវិធីអប្បបរិមានៃបណ្តឹងរដ្ឋ*

## 34 CFR §300.152

### *កម្រិតពេលវេលា; នីតិវិធីអប្បបរិមា*

*ទីភ្នាក់ងាររដ្ឋនិមួយៗត្រូវតែដាក់ចូលក្នុងនីតិវិធីបណ្តឹងរដ្ឋរបស់ខ្លួន នូវកម្រិតពេលវេលា 60 ថ្ងៃប្រក្រតិទិន បន្ទាប់ពីបណ្តឹងមួយត្រូវបានដាក់ ដើម្បី:*

1. *អនុវត្តការស៊ើបអង្កេតផ្ទាល់កន្លែងដោយឯករាជ្យមួយ, ប្រសិនបើទីភ្នាក់ងារអប់រំរដ្ឋនោះកំណត់ថា ការស៊ើបអង្កេតមួយជាការចាំបាច់;*
2. *ឲ្យដើមបណ្តឹងមានឱកាសដាក់ពត៌មានបន្ថែម, ជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់, អំពីការចោទប្រកាន់នានាក្នុងបណ្តឹង;*
3. *ឲ្យមណ្ឌលអប់រំនោះ ឬទីភ្នាក់ងារសាធារណ:ដទៃ ឱកាសឆ្លើយតបទៅនឹងបណ្តឹង, រួមទាំង, យ៉ាងតិចបំផុត:* (a) *តាមជម្រើសរបស់ទីភ្នាក់ងារនោះ, សំណើដើម្បីដោះស្រាយបណ្តឹង;* ***និង*** (b) *ឱកាសដើម្បីឲ្យមាតាបិតា ដែលបានដាក់បណ្តឹង និងទីភ្នាក់ងារនោះ ព្រមព្រៀងដោយស្ម័គ្រចិត្តចូលរួមក្នុងការសម្រុះសម្រួល;*
4. *ពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញនូវពត៌មានទាក់ទងទាំងអស់ ហើយធ្វើការកំណត់ដោយឯករាជ្យមួយ ថាតើមណ្ឌលអប់រំឬទីភ្នាក់ងារសាធារណ:ដទៃ ជាអ្នករំលោភមាត្រានៃផ្នែក* B *នៃច្បាប់* IDEA *ឬយ៉ាងណា;* ***និង***
5. *ចេញសេចក្តីសំរេចជាលាយលក្ខណ៍អក្សរមួយចំពោះបណ្តឹង ដែលដោះស្រាយការចោទប្រកាន់និមួយៗនៅក្នុងបណ្តឹង ហើយមាន:* (a) *ការរកឃើញការណ៍ពិតនិងការសន្និដ្ឋាន;* ***និង*** (b) *ហេតុផលនៃការសំរេចជាចុងក្រោយរបស់ទីភ្នាក់ងារអប់រំរដ្ឋនោះ ។*

### *ការពន្យារពេល; សេចក្តីសំរេចចុងក្រោយ; ការអនុវត្តន៍*

*នីតិវិធីរបស់ទីភ្នាក់ងារអប់រំរដ្ឋ ដែលបានរៀបរាប់ខាងលើ ក៏ត្រូវតែ:*

1. *អនុញ្ញាតឲ្យមានការពន្យារពេលនៃរយ:ពេលកំណត់* 60 *ថ្ងៃប្រក្រតិទិននោះ ប្រសិនបើ:* (a) *កាល:ទេស:ពិសេស កើតមានទាក់ទិននឹងបណ្តឹងរដ្ឋជាក់លាក់ណាមួយ;* ***ឬ*** (b) *មាតាបិតានិងមណ្ឌលអប់រំ ឬទីភ្នាក់ងារសាធារណ:ដែលមានរឿង ស្ម័គ្រចិត្តព្រមព្រៀងពន្យារពេល ដើម្បីដោះស្រាយបញ្ហាតាមរយ:ការសម្រុះសម្រួល ឬវិធីផ្សេងទៀតនៃការដោះស្រាយជម្លោះ, ប្រសិនបើមាននៅក្នុងរដ្ឋ ។*
2. *មាននីតិវិធីសំរាប់ការអនុវត្តន៍ឲ្យមានប្រសិទ្ធិភាព នូវសេចក្តីសំរេចចុងក្រោយរបស់ទីភ្នាក់ងារអប់រំរដ្ឋ, ប្រសិនបើត្រូវការ, រួមមាន:* (a) *សកម្មភាពជំនួយបច្ចេកទេសនានា;* (b) *ការចរចា;* ***និង*** (c) *វិធានការកែតម្រូវនានា ដើម្បីសំរេចបាននូវការអនុវត្តន៍តាម ។*

### *បណ្តឹងរដ្ឋនិងសវនាការត្រឹមត្រូវតាមច្បាប់*

*ប្រសិនបើបណ្តឹងរដ្ឋជាលាយលក្ខណ៍អក្សរមួយ ត្រូវបានគេទទួល ដែលវាក៏ជាប្រធានបទនៃសវនាការត្រឹមត្រូវតាមច្បាប់មួយ ដូចដែលបានរៀបរាប់ក្រោមជំពូក* ***ការដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់*** *ដែរនោះ, ឬបណ្តឹងរដ្ឋនោះមានបញ្ហាចំរុះ ដែលបញ្ហាមួយឬច្រើន ជាផ្នែកមួយនៃសវនាការបែបនេះ, រដ្ឋត្រូវតែដាក់បណ្តឹងរដ្ឋ ឬផ្នែកណាមួយនៃបណ្តឹងរដ្ឋដែលកំពុងត្រូវបានដោះស្រាយក្នុងសវនាការត្រឹមត្រូវតាមច្បាប់*

*ដោយឡែក រហូតដល់សវនាការចប់ ។ បញ្ហាណាមួយក្នុងបណ្តឹងរដ្ឋ ដែលមិនមែនជាផ្នែកមួយនៃសវនាការត្រឹមត្រូវតាមច្បាប់ ត្រូវតែដោះស្រាយដោយប្រើពេលវេលាកំណត់និងនីតិវិធីដូចដែលបានរៀបរាប់ខាងលើ ។*

*ប្រសិនបើបញ្ហាមួយត្រូវបានគេលើកឡើងក្នុងបណ្តឹងរដ្ឋមួយ ត្រូវបានគេសំរេចក្នុងសវនាការត្រឹមត្រូវតាមច្បាប់ទាក់ទិននឹងភាគីដដែលនេះ (អ្នកនិងមណ្ឌលអប់រំ) លើកមុនរួចហើយ, នោះសេចក្តីសំរេចនៃសវនាការត្រឹមត្រូវតាមច្បាប់នោះត្រូវប្រតិបត្តិតាមលើបញ្ហានោះ ហើយទីភ្នាក់ងារអប់រំរដ្ឋត្រូវតែជំរាបដើមបណ្តឹងឲ្យដឹងថា សេចក្តីសំរេចនោះត្រូវតែប្រតិបត្តិតាម ។*

*បណ្តឹងមួយដែលចោទប្រកាន់ថាមណ្ឌលអប់រំឬទីភ្នាក់ងារសាធារណៈដទៃមានការខកខានមិនបានអនុវត្តតាមសេចក្តីសំរេចសវនាការត្រឹមត្រូវតាមច្បាប់ ត្រូវតែដោះស្រាយដោយទីភ្នាក់ងារអប់រំរដ្ឋ ។*

# *ការដាក់បណ្តឹងរដ្ឋ*

## 34 CFR §300.153

*អង្គការមួយឬបុគ្គលម្នាក់ អាចដាក់បណ្តឹងរដ្ឋជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា ក្រោមនីតិវិធីដូចបានរៀបរាប់ខាងលើ ។*

*បណ្តឹងរដ្ឋនោះត្រូវមាន:*

1. *សេចក្តីអះអាងថា មណ្ឌលអប់រំមួយឬទីភ្នាក់ងារសាធារណៈដទៃទៀត បានរំលោភមាត្រានៃផ្នែក* B *នៃច្បាប់* IDEA *ឬការអនុវត្តន៍បទបញ្ញត្តិ របស់វា នៅ 34 CFR Part 300;*
2. *ការណ៍ពិតដែលសេចក្តីអះអាងនោះផ្អែកលើ;*
3. *ហត្ថលេខានិងពត៌មានទាក់ទងនៃបុគ្គលធ្វើបណ្តឹង; និង*
4. *ប្រសិនបើការរំលោភដែលកំពុងត្រូវចោទប្រកាន់នោះទាក់ទិននិងកុមារណាម្នាក់ជាក់លាក់:*
   (a) *ឈ្មោះរបស់កុមារ និងអាសយដ្ឋាននៃទីលំនៅរបស់កុមារនោះ;*
   (b) *ឈ្មោះសាលារៀនដែលកុមារនោះកំពុងរៀន;*
   (c) *ក្នុងករណីកុមារឬយុវជនគ្មានផ្ទះសំបែង, ត្រូវមានពត៌មានទាក់ទងសំរាប់កុមារនោះ, និងឈ្មោះសាលារៀនដែលកុមារនោះកំពុងរៀន;*
   (d) *ការពិពណ៌នាអំពីចរិតនៃបញ្ហារបស់កុមារនោះ, រួមទាំងការណ៍ពិតនានាទាក់ទិននឹងបញ្ហានោះ;* ***និង***
   (e) *ដំណោះស្រាយដែលបានស្នើឡើងមួយនៃបញ្ហានោះ ដល់កំរិតដែលដឹងបាននិងមាន ចំពោះភាគីដាក់បណ្តឹង នៅពេលដែលបណ្តឹងនោះត្រូវដាក់ ។*

*បណ្តឹងនោះត្រូវចោទប្រកាន់ការរំលោភមួយ ដែលបានកើតឡើងមិនយូរជាងមួយឆ្នាំមុនថ្ងៃដែលបណ្តឹងនោះត្រូវគេទទួល ដូចដែលបានរៀបរាប់ក្រោមជំពូក* ***ការអនុវត្តន៍នីតិវិធីបណ្តឹងរដ្ឋ*** *។*

*ភាគីដាក់បណ្តឹងរដ្ឋនោះ ត្រូវបញ្ជូនបណ្តឹងនោះមួយច្បាប់ទៅឲ្យមណ្ឌលអប់រំ ឬទីភ្នាក់ងារសាធារណៈដទៃ ដែលបំរើកុមារនោះ នៅពេលដែលភាគីនោះដាក់បណ្តឹងនឹងទីភ្នាក់ងារអប់រំរដ្ឋ ។*

# នីតិវិធីបណ្តឹងត្រឹមត្រូវតាមច្បាប់

## ការដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់

## 34 CFR §300.507

*ទូទៅ*

*អ្នកឬមណ្ឌលអប់រំអាចដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់មួយអំពីបញ្ហាណាក៏ដោយ ដែលទាក់ទិននឹងសំណើឬការបដិសេធ មិនផ្តួចផ្តើម ឬកែប្រែអត្តសញ្ញាណកម្ម, ការវាយតំលៃ ឬការរកគ្រឹះស្ថានសិក្សាឲ្យកូនអ្នករៀន, ឬការផ្តល់ការសិក្សាអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ដល់កូនអ្នក ។*

*បណ្តឹងត្រឹមត្រូវតាមច្បាប់ ត្រូវចោទប្រកាន់លើការរំលោភដែលបានកើតឡើងមិនលើសពីរយៈពេលពីរឆ្នាំ មុនពេលអ្នកឬមណ្ឌលអប់រំបានដឹងឬគួរបានដឹងអំពីសកម្មភាពដែលបានចោទប្រកាន់ ដែលបង្កើតជាមូលដ្ឋាននៃបណ្តឹងត្រឹមត្រូវតាមច្បាប់នោះ ។*

*ពេលវេលាកំណត់ខាងលើមិនអនុវត្តចំពោះអ្នកឡើយ ប្រសិនបើអ្នកមិនអាចដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ក្នុងរយៈពេលកំណត់នោះដោយមូលហេតុ:*

1. *មណ្ឌលអប់រំ ជាការជាក់ស្តែង បានថ្លែងមិនពិត ថាខ្លួនបានដោះស្រាយបញ្ហាទាំងឡាយ ដែលបានសំគាល់ក្នុងបណ្តឹងនោះ; **ឬ***
2. *មណ្ឌលអប់រំបានដកទុកពត៌មានពីអ្នក ដែលតម្រូវឲ្យផ្តល់ដល់អ្នក ក្រោមផ្នែក B នៃច្បាប់ IDEA ។*

***ពត៌មានសំរាប់មាតាបិតា***

*មណ្ឌលអប់រំត្រូវជំរាបអ្នកអំពីសេវាផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬគិតថ្លៃថោកៗ ឬសេវាទាក់ទិនផ្សេងៗទៀតដែលមាននៅក្នុងតំបន់ ប្រសិនបើអ្នកស្នើសុំពត៌មាន; **ឬ** ប្រសិនបើមណ្ឌលអប់រំដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ។*

## បណ្តឹងត្រឹមត្រូវតាមច្បាប់

## 34 CFR §300.508

*ទូទៅ*

*ដើម្បីស្នើសុំឲ្យមានសវនាការមួយ, អ្នកឬមណ្ឌលអប់រំ (ឬមេធាវីរបស់អ្នក ឬមេធាវីរបស់មណ្ឌលអប់រំ) ត្រូវដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ទៅឲ្យភាគីម្ខាងទៀត ។ បណ្តឹងនោះត្រូវមានពត៌មានទាំងអស់ដែលមានរាយខាងក្រោម ហើយត្រូវរក្សាជាការសម្ងាត់ ។*

*អ្នកឬមណ្ឌលអប់រំ, នរណាមួយជាអ្នកបានដាក់បណ្តឹង, ក៏ត្រូវផ្តល់បណ្តឹងនោះមួយច្បាប់ទៅឲ្យទីភ្នាក់ងារអប់រំរដ្ឋ ផងដែរ ។*

***ពត៌មាននៃបណ្តឹង***

*បណ្តឹងត្រឹមត្រូវតាមច្បាប់ត្រូវមាន:*

1. *ឈ្មោះរបស់កុមារ;*
2. *អាសយដ្ឋាននៃទីលំនៅរបស់កុមារ;*
3. *ឈ្មោះសាលារៀនរបស់កុមារ;*
4. *ប្រសិនបើកុមារឬយុវជននោះគ្មានផ្ទះសំបែង, ត្រូវមានពត៌មានទាក់ទងនិងឈ្មោះសាលារៀនរបស់កុមារនោះ;*
5. *ការពិពណ៌នាមួយអំពីចរិតនៃបញ្ហានៃកុមារដែលទាក់ទិននឹងវិធានការដែលបានស្នើឬបដិសេធ, រួមទាំងការណ៍ពិតទាក់ទិននឹងបញ្ហានោះផង; **និង***

6. *ដំណោះស្រាយដែលបានស្នើឡើងមួយនៃបញ្ហានោះ ដល់កម្រិតដែលបានដឹងនិងមាន ចំពោះបុគ្គលប្តឹង (អ្នកឬមណ្ឌលអប់រំ) នៅពេលនោះ ។*

### *សេចក្តីជូនដំណឹងដែលត្រូវមាន មុនសវនាការលើបណ្តឹងត្រឹមត្រូវតាមច្បាប់*

*អ្នកឬមណ្ឌលអប់រំមិនអាចមានសវនាការត្រឹមត្រូវតាមច្បាប់បានឡើយ រហូតដល់អ្នកឬមណ្ឌលអប់រំ (ឬមេធាវីរបស់អ្នកឬមេធាវីរបស់មណ្ឌលអប់រំ), ដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ដែលមានពត៌មានដូចមានរាយខាងលើ ។*

### *ភាពគ្រប់គ្រាន់នៃបណ្តឹង*

*ដើម្បីឲ្យបណ្តឹងត្រឹមត្រូវតាមច្បាប់មួយទៅមុខបាន, វាត្រូវតែបានគេចាត់ទុកថាគ្រប់គ្រាន់ ។ បណ្តឹងត្រឹមត្រូវតាមច្បាប់នឹងត្រូវគេចាត់ទុកថាគ្រប់គ្រាន់ (បានឆ្លើយតបនឹងពត៌មានត្រូវការខាងលើ) លើកលែងតែភាគីទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់នោះ (អ្នកឬមណ្ឌលអប់រំ) ឲ្យដំណឹងទៅមន្ត្រីសវនាការនិងភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ, ក្នុងរយៈ15 ថ្ងៃប្រក្រតិទិន នៃការទទួលបណ្តឹងនោះ, ថាភាគីទទួលជឿជាក់ថា បណ្តឹងត្រឹមត្រូវតាមច្បាប់នោះមិនឆ្លើយតបទៅនឹងតម្រូវការដូចមានរាយខាងលើឡើយ ។*

*ក្នុងរយៈប្រាំថ្ងៃប្រក្រតិទិននៃការទទួលការឲ្យដំណឹង ភាគីទទួល(អ្នកឬមណ្ឌលអប់រំ) ចាត់ទុកបណ្តឹងត្រឹមត្រូវតាមច្បាប់មួយថាមិនគ្រប់គ្រាន់, នោះមន្ត្រីសវនការត្រូវតែសំរេច ថាតើបណ្តឹត្រឹមត្រូវតាមច្បាប់នោះឆ្លើយតបទៅនឹងតម្រូវការដូចមានរាយខាងលើឬទេ, ហើយត្រូវឲ្យដំណឹងដល់អ្នកនិងមណ្ឌលអប់រំ ជាលាយលក្ខណ៍អក្សរជាបន្ទាន់ ។*

### *ការកែប្រែបណ្តឹង*

*អ្នកឬមណ្ឌលអប់រំ អាចធ្វើការកែប្រែបណ្តឹងបានតែក្នុងករណី:*

1. *ភាគីម្ខាងទៀតអនុមតិយល់ព្រមចំពោះការកែប្រែនោះជាលាយលក្ខណ៍អក្សរ ហើយត្រូវបានផ្តល់ឱកាសដើម្បីដោះស្រាយបណ្តឹងត្រឹមត្រូវតាមច្បាប់នោះ តាមរយៈអង្គប្រជុំរកដំណោះស្រាយ, ដូចចែង/ក្រោមជំពូក ដំណើរការនៃការដោះស្រាយ;* ***<u>ឬ</u>***
2. *មិនលើសពីប្រាំថ្ងៃ មុនពេលសវនាការត្រឹមត្រូវតាមច្បាប់ចាប់ផ្តើម, មន្ត្រីសវនាការឲ្យការអនុញ្ញាតសំរាប់ការកែប្រែទាំងនោះ ។*

*ប្រសិនបើភាគីប្តឹង (អ្នកឬមណ្ឌលអប់រំ) ធ្វើការកែប្រែបណ្តឹងត្រឹមត្រូវតាមច្បាប់, ពេលវេលាកំណត់សំរាប់អង្គប្រជុំរកដំណោះស្រាយ (ក្នុងរយៈ15 ថ្ងៃប្រក្រតិទិន នៃការទទួលបណ្តឹង) និងរយៈពេលសំរាប់ដំណោះស្រាយ (ក្នុងរយៈ 30 ថ្ងៃប្រក្រតិទិន នៃការទទួលបណ្តឹង) ចាប់ផ្តើមម្តងទៀតនៅថ្ងៃដែលបណ្តឹងដែលកែប្រែរួចនោះត្រូវដាក់ ។*

### *ការឆ្លើយតបរបស់ទីភ្នាក់ងារអប់រំមូលដ្ឋាន (LEA) ឬមណ្ឌលអប់រំ ចំពោះបណ្តឹងត្រឹមត្រូវតាមច្បាប់*

*ប្រសិនបើមណ្ឌលអប់រំមិនបានផ្ញើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យអ្នកជាមុន, ដូចបានរៀបរាប់ក្រោមជំពូក* ***សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ****, ទាក់ទិននឹងប្រធានបទដែលមានក្នុងបណ្តឹងត្រឹមត្រូវតាមច្បាប់របស់អ្នក, នោះមណ្ឌលអប់រំត្រូវ, ក្នុងរយៈពេល10 ថ្ងៃប្រក្រតិទិននៃការទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់, ផ្ញើឲ្យអ្នកនូវចំលើយមួយ ដែលមាន:*

1. *ការពន្យល់បកស្រាយមួយអំពីមូលហេតុដែលមណ្ឌលអប់រំបានស្នើឬបដិសេធ មិនចាត់វិធានការដែលបានលើកឡើងក្នុងបណ្តឹងត្រឹមត្រូវតាមច្បាប់នោះ;*
2. *ការពិពណ៌នាមួយអំពីជម្រើសផ្សេងៗទៀត ដែលក្រុមកម្មវិធីអប់រំបុគ្គលរបស់កូនអ្នក(IEP)បានពិចារណា និងហេតុផលដែលជម្រើសទាំងនោះត្រូវបានច្រានចោល;*
3. *ការពិពណ៌នាមួយអំពីនីតិវិធីនៃការវាយតំលៃ, ឯកសារ, ឬរបាយការណ៍នីមួយៗ ដែលមណ្ឌលអប់រំបានប្រើជាមូលដ្ឋាន សំរាប់វិធានការដែលបានស្នើឬបដិសេធ;* ***<u>និង</u>***
4. *ការពិពណ៌នាមួយអំពីកត្តាដទៃទៀត ដែលទាក់ទិននឹងវិធានការដែលបានស្នើឬបដិសេធ របស់មណ្ឌលអប់រំ ។*

*ការផ្តល់ពត៌មានក្នុងចំនុច 1-4 ខាងលើ មិនរារាំងមណ្ឌលអប់រំពីការអះអាងថា បណ្តឹងត្រឹមត្រូវតាមច្បាប់របស់អ្នកមិនគ្រប់គ្រាន់ ឡើយ ។*

***ការឆ្លើយតបរបស់ភាគីម្ខាងទៀតចំពោះបណ្តឹងត្រឹមត្រូវតាមច្បាប់***

*លើកលែងតែដូចបានបញ្ជាក់ក្រោមជំពូករង់ក្លាមៗខាងលើនេះ, **ការឆ្លើយតបរបស់ទីភ្នាក់ងារអប់រំមូលដ្ឋាន (LEA) ឬមណ្ឌលអប់រំ ចំពោះបណ្តឹងត្រឹមត្រូវតាមច្បាប់**, ភាគីទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់ ត្រូវតែ, ក្នុងរយៈពេល* 10 *ថ្ងៃប្រក្រតិទិននៃការទទួលបណ្តឹងនោះ, ផ្ញើទៅឲ្យភាគីម្ខាងទៀតនូវការឆ្លើយតបមួយ ដែលដោះស្រាយបញ្ហាជាក់លាក់នានាក្នុងបណ្តឹងនោះ ។*

# *ពាក្យបណ្តឹងគំរូ*

## 34 CFR §300.509

*ទីភ្នាក់ងារអប់រំរដ្ឋបានបង្កើតពាក្យបណ្តឹងគំរូ ដើម្បីជួយអ្នកធ្វើពាក្យបណ្តឹងត្រឹមត្រូវតាមច្បាប់ និង ជួយអ្នក និង បុគ្គលផ្សេងទៀតធ្វើបណ្តឹង រដ្ឋ ។ ប៉ុន្តែ, រដ្ឋ រឺ មណ្ឌលអប់រំ របស់អ្នកមិនតម្រូវឲ្យប្រើ ពាក្យបណ្តឹងគំរូទាំងនេះឡើយ ។ តាមពិត, អ្នកអាចប្រើគំរូនេះ ឬគំរូសមស្របផ្សេងទៀត, ដរាបណាវាមានពត៌មានដែលតម្រូវឲ្យមាន សំរាប់ដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ឬបណ្តឹងរដ្ឋ ។ ដើម្បីបានពាក្យបណ្តឹងគំរូ អ្នកអាចធ្វើដូចខាងក្រោមនេះ:*

1. *ចម្លងទុកពីវ៉ិបសៃថ៍* (web site) – [http://www.dese.mo.gov/divspeced/Complaint_System/index.htm](http://www.dese.mo.gov/divspeced/Complaint_System/index.htm)
2. *ទូរស័ព្ទទៅ នាយកដ្ឋានអប់រំបឋមសិក្សានិងមធ្យមសិក្សារដ្ឋមីស៊ួរី តាមលេខ* (573) 751-0602 ។

# *ការសម្រុះសម្រួល*

## 34 CFR §300.506

***ទូទៅ***

*ទីភ្នាក់ងារអប់រំរដ្ឋ ត្រូវតែធ្វើឲ្យមានការសម្រុះសម្រួល ដើម្បីឲ្យអ្នកនិងមណ្ឌលអប់រំដោះស្រាយទំនាស់ផ្សេងៗទាក់ទិននឹងបញ្ហាណាមួយ ក្រោមផ្នែក* B *នៃច្បាប់* IDEA, *រួមទាំងបញ្ហាដែលកើតមានមុនពេលដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ផងដែរ ។ ដូច្នេះ, ការសម្រុះសម្រួលគឺមានជាស្រេចសំរាប់ដោះស្រាយទំនាស់នានា ក្រោមផ្នែក* B *នៃច្បាប់* IDEA, *ទោះបីជាអ្នកបានឬមិនបានដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ដើម្បីស្នើឲ្យមានសវនាការដូចដែលបានរៀបរាប់ក្រោមជំពូក **ការដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់** ក៏ដោយ ។*

***តម្រូវការ***

*នីតិវិធីទាំងនេះត្រូវតែធានាថា ដំណើរការសម្រុះសម្រួស:*

1. *ជាការស្ម័គ្រចិត្តដោយផ្នែកខាងអ្នក និងផ្នែកខាងមណ្ឌលអប់រំ;*
2. *មិនត្រូវប្រើដើម្បីបដិសេធ ឬពន្យារសិទ្ធិរបស់អ្នកក្នុងការឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់, ឬដើម្បីបដិសេធសិទ្ធិណាមួយផ្សេងទៀតដែលអ្នកមាន ក្រោមផ្នែក* B *នៃច្បាប់* IDEA *ឡើយ;* ***និង***
3. *ត្រូវធ្វើឡើងដោយអ្នកសម្រុះសម្រួលដែលមានសមត្ថភាពនិងមិនលំអៀង ដែលបានទទួលការបណ្តុះបណ្តាលផ្នែកវិធីសម្រុះសម្រួលដែលមានប្រសិទ្ធិភាព ។*

*ដើម្បីស្នើសុំការសម្រុះសម្រួល សូមផ្ញើសំណើជាលាយលក្ខណ៍អក្សរទៅ:*

Missouri Department of Elementary and Secondary Education
Division of Special Education/Compliance Section
PO Box 480
Jefferson City, MO 65102-0480

*មណ្ឌលអប់រំអាចបង្កើតនីតិវិធីដែលផ្តល់ឲ្យមាតាបិតានិងសាលារៀនដែលជ្រើសរើសមិនប្រើប្រាស់ដំណើរការសម្រុះសម្រួល នូវឱកាសជួបគ្នា, នៅពេលណាមួយនិងទីកន្លែងណាមួយដែលងាយស្រួលដល់អ្នក, ជាមួយនឹងភាគីមិនលំអៀងមួយ:*

1. *ដែលស្ថិតក្រោមកិច្ចសន្យាជាមួយនឹងអង្គភាពដោះស្រាយទំនាស់មួយផ្សេងទៀតដែលសមស្រប, ឬមជ្ឈមណ្ឌលពត៌មាននិងបណ្តុះបណ្តាលមាតាបិតា ឬមជ្ឈមណ្ឌលធនធានសំរាប់មាតាបិតាប្រចាំសហគមន៍ក្នុងរដ្ឋ;* ***និង***
2. *ដែលនឹងពន្យល់អំពីផលប្រយោជន៍ ព្រមទាំងជំរុញការប្រើប្រាស់ដំណើរការសម្រុះសម្រួលដល់អ្នក ។*

*រដ្ឋត្រូវតែមានបញ្ជីមនុស្សដែលជាអ្នកសម្រុះសម្រួលមានសមត្ថភាព និងចេះដឹងច្បាប់និងបទបញ្ញត្តទាក់ទិននឹងការផ្តល់សេវាអប់រំពិសេស និងសេវាទាក់ទិនផ្សេងទៀត ។ ទីភ្នាក់ងារអប់រំរដ្ឋ ត្រូវតែជ្រើសរើសអ្នកសម្រុះសម្រួលតាមវិធីវិលជុំ, ព្រាវៗ, ឬវិធីមិនលំអៀងផ្សេងទៀត។*

*រដ្ឋជាអ្នកទទួលខុសត្រូវលើចំណាយនៃដំណើរការសម្រុះសម្រួលនោះ, រួមទាំងចំណាយនៃការប្រជុំផង ។*

*ការប្រជុំនិមួយៗក្នុងដំណើរការសម្រុះសម្រួល ត្រូវតែដាក់ពេលឲ្យបានទៀងទាត់ និងធ្វើឡើងនៅកន្លែងមួយដែលងាយស្រួលសំរាប់អ្នក និងមណ្ឌលអប់រំ ។*

*ប្រសិនបើអ្នកនិងមណ្ឌលអប់រំដោះស្រាយជម្លោះមួយតាមរយៈដំណើរការសម្រុះសម្រួល, ភាគីទាំងពីរត្រូវតែមានកិច្ចព្រមព្រៀងដែលមានប្រសិទ្ធិភាពផ្លូវច្បាប់ ដែលរៀបរាប់អំពីដំណោះស្រាយ និងដែល:*

1. *អះអាងថា រាល់ការពិភាក្សាទាំងអស់ដែលបានកើតឡើងក្នុងដំណើរការសម្រុះសម្រួលនោះ នឹងនៅជាការសម្ងាត់ និងមិនអាចត្រូវប្រើជាភស្តុតាងក្នុងសវនាការត្រឹមត្រូវតាមច្បាប់ឬរឿងក្តីរដ្ឋប្បវេណីដែលកើតមានឡើងនៅពេលក្រោយឡើយ (ក្តីតុលាកា);* ***និង***
2. *ត្រូវចុះហត្ថលេខាដោយទាំងអ្នកនិងទាំងអ្នកតំណាងមណ្ឌលអប់រំដែលមានអំណាចបង្គាប់មណ្ឌលអប់រំឲ្យគោរពតាម ។*

*កិច្ចព្រមព្រៀងសម្រុះសម្រួលជាលាយលក្ខណ៍អក្សរដែលមានចុះហត្ថលេខាមួយ គឺអាចពង្រឹងបានក្នុងតុលាការរដ្ឋណាមួយដែលមានសមត្ថកិច្ច (តុលាការដែលមានអំណាចក្រោមច្បាប់រដ្ឋ ក្នុងការកាត់សេចក្តីករណីបែបនេះ) ឬតុលាការប្រចាំតំបន់នៃសហរដ្ឋអាមេរិក ។*

*ការពិភាក្សានានាដែលកើតឡើងក្នុងដំណើរការសម្រុះសម្រួល ត្រូវតែជាការសម្ងាត់ ។ វាមិនអាចត្រូវប្រើជាភស្តុតាងក្នុងសវនាការត្រឹមត្រូវតាមច្បាប់ឬរឿងក្តីរដ្ឋប្បវេណីនាពេលអនាគតណាមួយនៃតុលាការសហព័ន្ធ ឬតុលាការរដ្ឋនៃរដ្ឋដែលទទួលជំនួយក្រោមផ្នែក* B *នៃច្បាប់* IDEA *ឡើយ ។*

### ភាពមិនលំអៀងនៃអ្នកសម្រុះសម្រួល

*អ្នកសម្រុះសម្រួល:*

1. *មិនអាចជាបុគ្គលិករបស់ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំដែលជាប់ទាក់ទិនក្នុងការសិក្សាអប់រំឬការមើលថែរកូនអ្នកឡើយ;* ***និង***
2. *មិនត្រូវមានប្រយោជន៍ផ្ទាល់ខ្លួនឬអាជីពដែលប៉ះពាល់ដល់ភាពមិនលំអៀងរបស់អ្នកសម្រុះសម្រួលឡើយ ។*

*បុគ្គលម្នាក់ដែលបើមិនអីចឹងទេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ធ្វើជាអ្នកសម្រុះសម្រួល គឺមិនមែនជាបុគ្គលិករបស់មណ្ឌលអប់រំឬទីភ្នាក់ងាររដ្ឋ ដោយគ្រាន់តែគេទទួលកំរៃពីទីភ្នាក់ងារឬមណ្ឌលអប់រំនោះ ឲ្យធ្វើជាអ្នកសម្រុះសម្រួលម្នាក់ប៉ុណ្ណោះ ។*

# ដំណើរការនៃការដោះស្រាយ

## 34 CFR §300.510

### ការប្រជុំរកដំណោះស្រាយ

*ក្នុងរយៈពេល*15 *ថ្ងៃប្រក្រតិទិននៃការទទួលសេចក្តីជូនដំណឹងអំពីបណ្តឹងត្រឹមត្រូវតាមច្បាប់របស់អ្នក, និងមុនសវនាការត្រឹមត្រូវតាមច្បាប់ចាប់ផ្តើម, មណ្ឌលអប់រំត្រូវកោះប្រជុំមួយជាមួយអ្នកនិងសមាជិកម្នាក់ឬច្រើនអ្នកនៃក្រុមកម្មវិធីអប់រំបុគ្គល* (IEP) *ដែលមានការដឹងឮជាក់លាក់អំពីការណ៍ពិតដែលមានក្នុងបណ្តឹងត្រឹមត្រូវតាមច្បាប់របស់អ្នក ។ អង្គប្រជុំនោះ:*

1. *ត្រូវមានអ្នកតំណាងរបស់មណ្ឌលអប់រំ ដែលមានអំណាចធ្វើការសំរេច ក្នុងនាមមណ្ឌលអប់រំ;* ***និង***

2. មិនអាចមានមេធាវីរបស់មណ្ឌលអប់រំឡើយ លើកលែងតែអ្នកក៏មានមេធាវីមកជាមួយដែរ ។

អ្នកនិងមណ្ឌលអប់រំជាអ្នកកំណត់សមាជិកជាប់ទាក់ទងរបស់ក្រុម IEP ឲ្យចូលរួមប្រជុំ ។

គោលបំណងនៃអង្គប្រជុំគឺសំរាប់អ្នកធ្វើការពិភាក្សាបណ្ដឹងត្រឹមត្រូវតាមច្បាប់របស់អ្នក, និងការណ៍ពិតដែលបង្កើតជាមូលដ្ឋាននៃបណ្ដឹងនោះ, ដើម្បីឲ្យមណ្ឌលអប់រំមានឱកាសដោះស្រាយជម្លោះ ។

អង្គប្រជុំរកដំណោះស្រាយមិនចាំបាច់មានឡើយ ប្រសិនបើ:

1. អ្នកនិងមណ្ឌលអប់រំព្រមព្រៀងជាលាយលក្ខណ៍អក្សរ ថាមិនបាច់មានការប្រជុំ; **ឬ**
2. អ្នកនិងមណ្ឌលអប់រំព្រមព្រៀងប្រើដំណើរការសម្រុះសម្រួល, ដូចបានរៀបរាប់ក្រោមជំពូក ***ការសម្រុះសម្រួល*** ។

### រយៈពេលដំណោះស្រាយ

ប្រសិនបើមណ្ឌលអប់រំមិនទាន់បានដោះស្រាយបណ្ដឹងត្រឹមត្រូវតាមច្បាប់ឲ្យបានជាទីពេញចិត្តរបស់អ្នក ក្នុងរយៈពេល 30 ថ្ងៃប្រក្រតិទិន បន្ទាប់ពីបានទទួលបណ្ដឹងត្រឹមត្រូវតាមច្បាប់ (ក្នុងកំឡុងរយៈពេលសំរាប់ដំណើរការដំណោះស្រាយ) ទេ, នោះសវនាការអាចកើតឡើង ។

រយៈពេលកំណត់ 45 ថ្ងៃប្រក្រតិទិន សំរាប់ចេញសេចក្ដីសំរេច*ដំណើរការសវនាការ*ចុងក្រោយ, ដូចមានចែងនៅជំពូក, *សំរេចសវនាការ,* ចាប់ផ្ដើមនៅពេលរយៈពេលរកដំណោះ 30 ថ្ងៃប្រក្រតិទិនផុត កំណត់,
ដោយមានការលើកលែងខ្លះសំរាប់ការកែសំរួលធ្វើឡើងចំពោះរយៈពេលរកដំណោះស្រាយ 30 ថ្ងៃប្រក្រតិទិន, ដូចរៀបរាប់ខាង ក្រោម ។ លើកលែងតែពេលដែលអ្នកនិងមណ្ឌលអប់រំ ទាំងសង្ខាង បានព្រមព្រៀងថាមិនចាំបាច់ឲ្យមានដំណើរការរកដំណោះស្រាយ ឬប្រើការសម្រុះសម្រួលចេញ, ការខកខានរបស់អ្នកមិនបានមកចូលរួមក្នុងអង្គប្រជុំរកដំណោះស្រាយនឹងធ្វើឲ្យមានការពន្យារពេលសំរាប់ដំណើរការរកដំណោះស្រាយនិងសវនាការត្រឹមត្រូវតាមច្បាប់ រហូតដល់ពេលអង្គប្រជុំចាប់ផ្ដើម ។

ប្រសិនបើបន្ទាប់ពីបានខិតខំប្រឹងប្រែងយ៉ាងសមស្រប ហើយបានកត់ត្រាការខិតខំប្រឹងប្រែងនោះរួចមក, មណ្ឌលអប់រំមិនអាចធ្វើឲ្យអ្នកចូលក្នុងអង្គប្រជុំរកដំណោះស្រាយ, មណ្ឌលអប់រំអាច, នៅចុងបញ្ចប់នៃរយៈពេលរកដំណោះស្រាយ 30 ថ្ងៃប្រក្រតិទិន, ស្នើសុំឲ្យមន្ត្រីសវនាការទាត់ចោលបណ្ដឹងត្រឹមត្រូវតាមច្បាប់របស់អ្នក ។ កំណត់ត្រានៃការខិតខំប្រឹងប្រែងបែបនោះ ត្រូវតែមានបញ្ចូលនូវកំណត់ត្រាអំពីការប៉ុនប៉ងនានារបស់មណ្ឌលអប់រំ ក្នុងការរៀបចំឲ្យមានម៉ោងពេលនិងទីកន្លែងដែលបានព្រមព្រៀងទៅវិញទៅមក, ដូចជា:

1. កំណត់ត្រាពិស្ដារអំពីការហៅទូរស័ព្ទដែលបានធ្វើឡើងឬប៉ុនប៉ងធ្វើ និងលទ្ធផលនៃការហៅទាំងនោះ;
2. ច្បាប់ចំឡងនៃលិខិតនានាដែលបានផ្ញើទៅឲ្យអ្នក និងការឆ្លើយតបនានាដែលបានទទួល, និង
3. កំណត់ត្រាពិស្ដារអំពីការទៅកាន់ផ្ទះអ្នក ឬទីកន្លែការងារអ្នក និងលទ្ធផលនៃដំណើរទាំងនោះ ។

ប្រសិនបើមណ្ឌលអប់រំខកខានមិនបានធ្វើការប្រជុំរកដំណោះស្រាយក្នុងរយៈ15 ថ្ងៃប្រក្រតិទិនបន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងអំពីបណ្ដឹងត្រឹមត្រូវតាមច្បាប់របស់អ្នក **ឬ** ខកខានមិនបានចូលរួមក្នុងអង្គប្រជុំរកដំណោះស្រាយ, អ្នកអាចស្នើសុំឲ្យមន្ត្រីសវនាការចាប់ផ្ដើមរយៈពេលសវនាការត្រឹមត្រូវតាមច្បាប់ 45 ថ្ងៃប្រក្រតិទិននោះ។

### ការកែសម្រួលធ្វើឡើងចំពោះរយៈពេលរកដំណោះស្រាយ30 ថ្ងៃប្រក្រតិទិន

ប្រសិនបើអ្នកនិងមណ្ឌលអប់រំព្រមព្រៀងជាលាយលក្ខណ៍អក្សរថាមិនបាច់ឲ្យមានការប្រជុំរកដំណោះស្រាយទេ, នោះរយៈពេល 45 ថ្ងៃប្រក្រតិទិន សំរាប់សវនាការត្រឹមត្រូវតាមច្បាប់ ចាប់ផ្ដើមនៅថ្ងៃបន្ទាប់ ។

បន្ទាប់ពីការចាប់ផ្ដើមនៃការសម្រុះសម្រួល ឬអង្គប្រជុំរកដំណោះស្រាយ និងមុនរយៈពេលរកដំណោះស្រាយ 30 ថ្ងៃប្រក្រតិទិន ចប់, ប្រសិនបើអ្នកនិងមណ្ឌលអប់រំព្រមព្រៀងជាលាយលក្ខណ៍អក្សរថា មិនអាចមានកិច្ចព្រមព្រៀងបានទេ, នោះរយៈពេល 45 ថ្ងៃប្រក្រតិទិន សំរាប់សវនាការត្រឹមត្រូវតាមច្បាប់ចាប់ផ្ដើមនៅថ្ងៃបន្ទាប់ ។

ប្រសិនបើអ្នកនិងមណ្ឌលអប់រំព្រមព្រៀងប្រើដំណើរការសម្រុះសម្រួល, នៅចុងបញ្ចប់នៃរយៈពេលរកដំណោះស្រាយ ប៉ុន្តែពុំទាន់មានកិច្ចព្រមព្រៀង, នៅចុង 30 ថ្ងៃប្រក្រតិទិន កំលុងពេលដោះស្រាយ, ដំណើរការរកដំណោះស្រាយត្រូវ
បានបន្តរហូតដល់មានមានការព្រមព្រៀងមួយឡើង បើសិនភាគីទាំងសងខាងយល់ព្រមបន្តរជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែ, ប្រសិន

*បើអ្នកឬមណ្ឌលអប់រំ នរណាមួយដកខ្លួនចេញពីដំណើរការសម្រុះសម្រួល, នោះរយៈពេល 45 ថ្ងៃប្រក្រតិទិនសំរាប់សវនាការត្រឹមត្រូវតាមច្បាប់ចាប់ផ្តើមនៅថ្ងៃបន្ទាប់ ។*

### ***កិច្ចព្រមព្រៀងដំណោះស្រាយជាលាយលក្ខណ៍អក្សរ***

*ប្រសិនបើដំណោះស្រាយមួយនៃជម្លោះនោះកើតមានឡើងនៅឯអង្គប្រជុំរកដំណោះស្រាយ, អ្នកនិងមណ្ឌលអប់រំត្រូវមានកិច្ចព្រមព្រៀងដែលមានប្រសិទ្ធិភាពផ្លូវច្បាប់មួយ ដែល:*

1. *ចុះហត្ថលេខាដោយអ្នកនិងអ្នកតំណាងមណ្ឌលអប់រំម្នាក់ដែលមានអំណាចបង្គាប់ឲ្យមណ្ឌលអប់រំគោរពតាម;* ***<u>និង</u>***
2. *អាចពង្រឹងបានក្នុងតុលាការរដ្ឋមានសមត្ថកិច្ចណាមួយ (តុលាការរដ្ឋដែលមានអំណាចកាត់សេចក្តីករណីបែបនេះ) ឬក្នុងតុលាការប្រចាំតំបន់របស់សហរដ្ឋអាមេរិកមួយ ឬដោយទីភ្នាក់ងារអប់រំរដ្ឋ, ប្រសិនបើរដ្ឋរបស់អ្នកមានយន្តការឬនីតិវិធីផ្សេងទៀត ដែលអនុញ្ញាតឲ្យភាគីជម្លោះរកការពង្រឹងកិច្ចព្រមព្រៀងដំណោះស្រាយនានា ។*

### ***រយៈពេលពិនិត្យកិច្ចព្រមព្រៀងយ៉ាងហ្មត់ចត់ឡើងវិញ***

*ប្រសិនបើអ្នកនិងមណ្ឌលអប់រំសំរេចបាននូវកិច្ចព្រមព្រៀងមួយជាលទ្ធផលនៃការប្រជុំរកដំណោះស្រាយ, នោះភាគីណាមួយ (អ្នកឬមណ្ឌលអប់រំ) អាចទុកកិច្ចព្រមព្រៀងនោះជាមោឃៈ ក្នុងរយៈពេល 3 ថ្ងៃធ្វើការ នៃពេលដែលទាំងសង្ខាង អ្នកនិងមណ្ឌលអប់រំ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះ ។*

# *សវនាការដោះស្រាយបណ្តឹងត្រឹមត្រូវតាមច្បាប់*

## *សវនាការបណ្តឹងត្រឹមត្រូវតាមច្បាប់*

## 34 CFR §300.511

### ***ទូទៅ***

*នៅពេលណាដែលបណ្តឹងត្រឹមត្រូវតាមច្បាប់មួយត្រូវបានដាក់, អ្នកឬមណ្ឌលអប់រំដែលទាក់ទិនក្នុងជម្លោះ ត្រូវមានឱកាសមានសវនាការត្រឹមត្រូវតាមច្បាប់មួយ, ដូចបានរៀបរាប់ក្នុងផ្នែក* ***បណ្តឹងត្រឹមត្រូវតាមច្បាប់*** *និងផ្នែក* ***ដំណើរការរកដំណោះស្រាយ*** *។*

*សំណើរឲ្យមានបណ្តឹងត្រឹមត្រូវតាមច្បាប់ជាលាយលក្ខណ៍អក្សរ ត្រូវផ្ញើទៅនាយកដ្ឋានអប់រំផ្នែកបឋមសិក្សានិងមធ្យមសិក្សារដ្ឋមីស៊ូរី, ហើយត្រូវថតចំលង រួចផ្ញើទៅទីភ្នាក់ងារដែលអ្នកប្តឹងត្រឹមត្រូវតាមច្បាប់នោះ ។*

*អាសយដ្ឋានរបស់នាយកដ្ឋានគឺ:*

MODESE
Attention: Compliance Section/Special Education
PO Box 480
Jefferson City, MO 65102
*ទូរសារលេខ:* (573) 526-4404

### ***មន្ត្រីសវនាការមិនលំអៀង***

យ៉ាងហោចណាស់, មន្ត្រីសវនាការ:

1. មិនត្រូវជាបុគ្គលិករបស់ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំដែលទាក់ទិននឹងការសិក្សាអប់រំ ឬការមើលថែកុមារនោះឡើយ ។ ប៉ុន្តែ, បុគ្គលម្នាក់មិនមែនជាបុគ្គលិករបស់ទីភ្នាក់ងារ ដោយគ្រាន់តែគេត្រូវបានបង់ប្រាក់កំរៃដោយទីភ្នាក់ងារនោះឲ្យធ្វើជាមន្ត្រីសវនាការ តែមួយមុខប៉ុណ្ណោះទេ ។
2. មិនត្រូវមានប្រយោជន៍ផ្ទាល់ខ្លួនឬអាជីព ដែលប៉ះពាល់ដល់ភាពមិនលំអៀងរបស់មន្ត្រីសវនាការនោះ ក្នុងសវនាការនោះឡើយ;
3. ត្រូវមានចំណេះដឹងច្បាស់លាស់ និងយល់មាត្រានៃច្បាប់ IDEA, និងបទបញ្ញត្តរបស់រដ្ឋនិងសហព័ន្ធ ទាក់ទិននឹងច្បាប់ IDEA, ព្រមទាំងការបកស្រាយផ្លូវច្បាប់នៃច្បាប់ IDEA ដោយតុលាការរដ្ឋនិងតុលាការសហព័ន្ធ; **និង**
4. ត្រូវមានចំណេះដឹងនិងសមត្ថភាពធ្វើសវនាការ, និងធ្វើនិងសរសេរសេចក្តីសំរេច, សមស្របនឹងការអនុវត្តន៍ច្បាប់ជាស្តង់ដារ ។

មណ្ឌលអប់រំនីមួយៗត្រូវរក្សាទុកបញ្ជីបុគ្គលទាំងនោះដែលបំរើជាមន្ត្រីសវនាការ ដោយមានរៀបរាប់ពីលក្ខណៈសម្បត្តិគ្រប់គ្រាន់របស់មន្ត្រីនីមួយៗផង ។

### ប្រធានបទនៃសវនាការត្រឹមត្រូវតាមច្បាប់

ភាគី (អ្នកឬមណ្ឌលអប់រំ) ដែលស្នើសុំឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់ មិនអាចលើកឡើងបញ្ហានានានៅឯសវនាការត្រឹមត្រូវតាមច្បាប់ ដែលមិនបានត្រូវលើកឡើងក្នុងបណ្តឹងត្រឹមត្រូវតាមច្បាប់នោះឡើយ, លើកលែងតែភាគីម្ខាងទៀតយល់ព្រម ។

### ពេលវេលាកំណត់សំរាប់ស្នើសុំឲ្យមានសវនាការ

អ្នក ឬមណ្ឌលអប់រំ ត្រូវស្នើឲ្យមានសវនាការមិនលំអៀងមួយនៃបណ្តឹងត្រឹមត្រូវតាមច្បាប់ ឲ្យបានក្នុងរយៈពេលពីរឆ្នាំពីថ្ងៃដែលអ្នក ឬមណ្ឌលអប់រំបានដឹង ឬគួរបានដឹង អំពីបញ្ហាដែលបានត្រូវដោះស្រាយក្នុងបណ្តឹងនោះ ។

### ករណីលើកលែង ចំពោះពេលវេលាកំណត់

ពេលវេលាកំណត់ខាងលើមិនអនុវត្តចំពោះអ្នកឡើយ ប្រសិនបើអ្នកមិនអាចដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ដោយមូលហេតុ:

1. មណ្ឌលអប់រំដាក់ស្តែងបានថ្លែងមិនពិតថា ខ្លួនបានដោះស្រាយបញ្ហាឬរឿងដែលអ្នកកំពុងលើកឡើងក្នុងបណ្តឹងរបស់អ្នក; **ឬ**
2. មណ្ឌលអប់រំបិទបាំងពត៌មានពីអ្នក ដែលខ្លួនត្រូវផ្តល់ដល់អ្នក ក្រោមផ្នែក B នៃច្បាប់ IDEA ។

# សិទ្ធិសវនាការនានា

## 34 CFR §300.512

### ទូទៅ

អ្នកមានសិទ្ធិតំណាងខ្លួនអ្នកនៅសវនាការត្រឹមត្រូវតាមច្បាប់ ។ ជាបន្ថែម, ភាគីទាំងឡាយណាទាក់ទិននឹងសវនាការត្រឹមត្រូវតាមច្បាប់ណាក៏ដោយ (រួមទាំងសវនាការទាក់ទិននឹងនីតិវិធីដាក់វិន័យផង) មានសិទ្ធិ:

1. រួមដំណើរនិងផ្តល់ប្រឹក្សាដោយមេធាវីម្នាក់ និង/ឬ បុគ្គលមានចំណេះដឹងឬការបណ្តុះបណ្តាលពិសេស អំពីបញ្ហាកុមារមានពិការភាព;
2. ត្រូវបានតំណាងនៅសវនាការត្រឹមត្រូវតាមច្បាប់ដោយ មេធាវីម្នាក់;
3. បង្ហាញភស្តុតាងនិងប្រឈមមុខ, សួរចម្លើយ, និងស្នើឲ្យមានវត្តមានសាក្សី;
4. ហាមឃាត់ការបង្ហាញភស្តុតាងណាមួយនៅឯសវនាការ ដែលមិនទាន់បានបង្ហាញទៅភាគីនោះ យ៉ាងហោចណាស់រយៈពេលប្រាំថ្ងៃធ្វើការ មុនសវនាការនោះ;
5. យកឯកសារសវនាការដែលបានកត់ត្រាគ្រប់ពាក្យ ជាលាយលក្ខណ៍អក្សរ, ឬ, តាមចិត្តអ្នក, ជាអេឡិកត្រូនិក; **និង**

6. យកលទ្ធផលនៃការណ៍ពិតនិងសេចក្តីសំរេចនានា ជាលាយលក្ខណ៍អក្សរ, ឬ, តាមចិត្តអ្នក, ជាអេឡិចត្រូនិក ។

### ការបង្ហាញពត៌មានថែមទៀត

យ៉ាងហោចណាស់ប្រាំថ្ងៃធ្វើការមុនសវនាការត្រឹមត្រូវតាមច្បាប់, អ្នកនិងមណ្ឌលអប់រំ ត្រូវបង្ហាញឲ្យគ្នាទៅវិញទៅមក ការវាយតំលៃដទៃផ្សេងទៀតទាំងអស់ ដែលបានធ្វើឡើងចប់សព្វគ្រាប់មុនថ្ងៃនោះ ព្រមទាំងអនុសាសន៍នានាផ្អែកលើការវាយតំលៃទាំងនោះ ដែលអ្នកនិងមណ្ឌលអប់រំ មានបំណងចង់ប្រើប្រាស់នៅឯសវនាការ ។

មន្ត្រីសវនាការម្នាក់ អាចរាំងភាគីណាដែលខកខានមិនបានអនុវត្តតាមតម្រូវការនេះ មិនឲ្យបង្ហាញការវាយតំលៃដែលជាប់ទាក់ទិន នៅឯសវនាការ ដោយគ្មានការយល់ព្រមពីភាគីម្ខាងទៀត ។

### សិទ្ធិរបស់មាតាបិតា នៅឯសវនាការ

គេត្រូវតែផ្តល់សិទ្ធិដល់អ្នក:

1. មានវត្តមានកូនអ្នក;
2. បើកសវនាការឲ្យសាធារណៈជនចូលមើល; **និង**
3. មានឯកសារសវនាការ, លទ្ធផលនៃការណ៍ពិត និងសេចក្តីសំរេច ផ្តល់ដល់អ្នកដោយឥតគិតថ្លៃ ។

# សេចក្តីសំរេចសវនាការ

## 34 CFR §300.513

### សេចក្តីសំរេច របស់មន្ត្រីសវនាការ

សេចក្តីសំរេចរបស់មន្ត្រីសវនាការ ថាតើកូនអ្នកបានទទួលការសិក្សាអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ឬយ៉ាងណា ត្រូវតែផ្អែកលើភស្តុតាង និង សេចក្តីសំអាងដែលមានការពាក់ព័ន្ធនឹងការសិក្សាអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ ។

ក្នុងរឿងចោទប្រកាន់ការរំលោភនីតិវិធី (ដូចជា "ការមិនគ្រប់ IEP Team", មន្ត្រីសវនាការអាចរកឃើញថា កូនអ្នកមិនបានទទួល FAPE ប៉ុណ្ណោះ ប្រសិនបើបំពាន នីតិវិធីនោះ:

1. ជ្រៀតជ្រែកនឹងសិទ្ធិរបស់កូនអ្នក ក្នុងការទទួលការសិក្សាអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE);
2. ជ្រៀតជ្រែកយ៉ាងខ្លាំងនឹងឱកាសរបស់អ្នក ក្នុងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសំរេច ទាក់ទិននឹងការផ្តល់ការសិក្សាអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ដល់កូនអ្នក; **ឬ**
3. បានបណ្តាលឲ្យកូនអ្នកត្រូវបានដកហូតផលប្រយោជន៍នៃការអប់រំ ។

### ខសន្មត

គ្មានមាត្រាណាមួយនៃមាត្រាទាំងឡាយដែលរៀបរាប់ខាងលើ អាចត្រូវបកស្រាយក្នុងន័យរាំងមន្ត្រីសវនាការម្នាក់ពីការចេញបញ្ជាឲ្យមណ្ឌលអប់រំអនុវត្តតាមតម្រូវការ ក្នុងជំពូកស្តីពីកិច្ចការពារតាមនីតិវិធីនៃបទបញ្ញាសហព័ន្ធ ក្រោមផ្នែក B នៃច្បាប់ IDEA (ចាប់ពី 34 CFR §§300.500 ដល់ 300.536) ឡើយ ។

### សំណើដាច់ដោយឡែក សុំឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់មួយ

ក្នុងជំពូកស្តីពីកិច្ចការពារតាមនីតិវិធីនៃបទបញ្ញាសហព័ន្ធ ក្រោមផ្នែក B នៃច្បាប់ IDEA (ចាប់ពី 34 CFR §§300.500 ដល់ 300.536) គ្មានអ្វីអាចរាំងអ្នកមិនឲ្យដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ដាច់ដោយឡែកមួយ អំពីរឿងដោយឡែកមួយទៀតពីបណ្តឹងត្រឹមត្រូវតាមច្បាប់ដែលបានដាក់រួចហើយ នោះឡើយ ។

***លទ្ធផលនិងសេចក្តីសំរេច បង្ហាញជូនក្រុមផ្តល់ប្រឹក្សា និងសាធារណៈជន***

*ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំ (មួយណាជាអ្នកទទួលខុសត្រូវចំពោះសវនាការអ្នក) បន្ទាប់ពីយកចេញពត៌មានដែលអាចសំគាល់អត្តសញ្ញាណបុគ្គលរួច, ត្រូវ:*

1. *ផ្តល់លទ្ធផលនិងសេចក្តីសំរេចក្នុងសវនាការត្រឹមត្រូវតាមច្បាប់ឬបណ្តឹងឧទ្ធរណ៍ទាំងនោះ ទៅឲ្យក្រុមផ្តល់ប្រឹក្សាផ្នែកការសិក្សាអប់រំពិសេសរដ្ឋ;* ***និង***
2. *ដាក់លទ្ធផលនិងសេចក្តីសំរេចទាំងនោះ ជូនសាធារណៈជន*

# *បណ្តឹងឧទ្ធរណ៍*

## *ទីបញ្ចប់នៃសេចក្តីសំរេច; បណ្តឹងឧទ្ធរណ៍; ការពិនិត្យឡើងវិញដោយមិនលំអៀង*

### 34 CFR §300.514

***ទីបញ្ចប់នៃសេចក្តីសំរេចសវនាការ***

*សេចក្តីសំរេចមួយធ្វើឡើងក្នុងសវនាការត្រឹមត្រូវតាមច្បាប់ (រួមទាំងសវនាការទាក់ទិននឹងនីតិវិធីដាក់វិន័យ) គឺជាសេចក្តីសំរេចចុងក្រោយ, លើកលែងតែក្នុងករណីដែលភាគីណាមួយក្នុងសវនាការ (អ្នកឬមណ្ឌលអប់រំ) អាចប្តឹងតវ៉ាសេចក្តីសំរេចនោះ ដោយនាំមកនូវបណ្តឹងរដ្ឋប្បវេណី, ដូចរៀបរាប់ខាងក្រោម: នៅក្នុងជំពូក****បណ្តឹង រដ្ឋប្បវេណី, រួមទាំងរយៈពេលត្រូវដាក់ បណ្តឹងទាំងនោះ*** ។

## *ពេលវេលាកំណត់និងភាពងាយស្រួលនៃសវនាការនិងការពិនិត្យឡើងវិញ*

### 34 CFR §300.515

*ទីភ្នាក់ងារអប់រំរដ្ឋ ត្រូវធានាថា មិនលើសពី* 45 *ថ្ងៃប្រក្រតិទិន បន្ទាប់ពីផុតកំណត់រយៈពេល* 30 *ថ្ងៃប្រក្រតិទិន សំរាប់ការប្រជុំរកដំណោះស្រាយ* ***ឬ****, ដូចបានរៀបរាប់ក្រោមជំពូក* ***ការកែសម្រួលចំពោះរយៈពេលរកដំណោះស្រាយ 30 ថ្ងៃប្រក្រតិទិន***, មិនលើសពី 45 *ថ្ងៃប្រក្រតិទិន បន្ទាប់ពីផុតកំណត់រយៈពេលដែលបានកែសម្រួល:*

1. *សេចក្តីសំរេចចុងក្រោយមួយត្រូវកើតមានឡើងក្នុងសវនាការ;* ***និង***
2. *សេចក្តីសំរេចចំឡងមួយច្បាប់ ត្រូវផ្ញើទៅឲ្យភាគីនីមួយៗ ។*

*មន្ត្រីសវនាការអាចផ្តល់ការពន្យារពេលជាក់លាក់មួយលើសពីរយៈពេល* 45 *ថ្ងៃប្រក្រតិទិនដែលបានរៀបរាប់ខាងលើ តាមសំណូមពរភាគីណាមួយ ។*

*សវនាការនិមួយៗត្រូវតែធ្វើឡើងនៅពេលនិងទីកន្លែងដែលងាយស្រួលសមស្របដល់អ្នកនិងកូនអ្នក ។*

# បណ្តឹងរដ្ឋប្បវេណី, រួមទាំងរយៈពេលដែលត្រូវដាក់បណ្តឹងទាំងនោះ

## 34 CFR §300.516

***ទូទៅ***

*ភាគីណាក៏ដោយ (អ្នកឬមណ្ឌលអប់រំ) ដែលមិនយល់ព្រមនឹងលទ្ធផលនិងសេចក្តីសំរេចក្នុងសវនាការត្រឹមត្រូវតាមច្បាប់នោះ (រួមទាំងសវនាការទាក់ទិននឹងនីតិវិធីដាក់វិន័យផង) មានសិទ្ធិដាក់បណ្តឹងរដ្ឋប្បវេណីចំពោះបញ្ហាដែលជាប្រធានបទនៃសវនាការត្រឹមត្រូវតាមច្បាប់នោះ ។ បណ្តឹងនោះអាចដាក់នៅក្នុងតុលាការរដ្ឋមានសមត្ថកិច្ច (តុលាការរដ្ឋដែលមានអំណាចកាត់សេចក្តីករណីបែបនេះ) ឬក្នុងតុលាការប្រចាំតំបន់របស់សហរដ្ឋអាមេរិក ដោយមិនគិតដល់បរិមាណក្នុងជម្លោះ ។*

***ការកំណត់ពេល***

*ភាគី (អ្នកឬមណ្ឌលអប់រំ) ដាក់បណ្តឹង ត្រូវមានពេល* 45 *ថ្ងៃប្រក្រតិទិន ចាប់ពីថ្ងៃសេចក្តីសំរេចរបស់មន្ត្រីសវនាការ ដើម្បីដាក់បណ្តឹងរដ្ឋប្បវេណី ។*

***នីតិវិធីបន្ថែម***

*ក្នុងបណ្តឹងរដ្ឋប្បវេណីណាក៏ដោយ, តុលាការៈ*

1. *ទទួលឯកសារនីតិវិធីរដ្ឋបាល;*
2. *ទទួលពិនិត្យភស្តុតាងបន្ថែមតាមសំណើរបស់អ្នក ឬតាមសំណើរបស់មណ្ឌលអប់រំ;* ***និង***
3. *ផ្អែកសេចក្តីសំរេចរបស់ខ្លួនលើឧត្តមានុភាពនៃភស្តុតាង និងផ្តល់ការជួសជុលដែលតុលាការកំណត់ថាសមស្រប ។*

*នៅកាលទេសៈសមរម្យ, សំរេចនៃច្បាប់រួមមានសំណងតំលៃសាលាឯកជន និង សេវាអប់រំប៉ះប៉ូវ។*

***ដែនសមត្ថកិច្ចរបស់តុលាការប្រចាំតំបន់***

*តុលាការប្រចាំតំបន់របស់សហរដ្ឋអាមេរិក មានអំណាចកាត់សេចក្តីបណ្តឹងនានា ក្រោមផ្នែក* B *នៃច្បាប់* IDEA *ដោយមិនគិតដល់បរិមាណក្នុងជម្លោះ ។*

***វិធាននៃការសន្មត***

*គ្មានអ្វីក្នុងផ្នែក* B *នៃច្បាប់* IDEA *ដាក់លក្ខខ័ណ្ឌឬដាក់កំហិតលើសិទ្ធិ, នីតិវិធី, និងមធ្យោបាយផ្លូវច្បាប់នានា ក្រោមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក, ច្បាប់ស្តីពីពលរដ្ឋអាមេរិកាំងមានពិការភាព ឆ្នាំ*1990*, ច្បាប់ស្តីពីការស្តារលទ្ធភាពឡើងវិញ*Title V *ឆ្នាំ*1973 *(ជំពូក* 504*),* *ឬច្បាប់សហព័ន្ធផ្សេងទៀតដែលការពារសិទ្ធិកុមារមានពិការភាព ឡើយ, លើកលែងតែ មុនពេលដាក់បណ្តឹងរដ្ឋប្បវេណីមួយក្រោមច្បាប់ទាំងនេះដើម្បីរកការជួសជុលដែលមានក្រោមផ្នែក* B *នៃច្បាប់* IDEA *ផងដែរ, នីតិវិធីត្រឹមត្រូវតាមច្បាប់ដូចបានរៀបរាប់ខាងលើ ត្រូវតែប្រើឲ្យអស់ ដល់កម្រិតដូចគ្នាដែលនឹងតម្រូវឲ្យធ្វើប្រសិនបើភាគីនោះដាក់បណ្តឹងក្រោមផ្នែក* B *នៃច្បាប់* IDEA *ដូច្នោះដែរ ។ នេះគឺមានន័យថា អ្នកអាចមានដំណោះស្រាយផ្លូវច្បាប់មានស្រាប់ ក្រោមច្បាប់ផ្សេងៗទៀត ដែលជាន់គ្នានឹងដំណោះស្រាយផ្លូវច្បាប់មានក្រោមច្បាប់* IDEA*, ប៉ុន្តែជាទូទៅ, ដើម្បីបានការជួសជុល ក្រោមច្បាប់ទាំងនោះ, ជាបឋមអ្នកត្រូវប្រើដំណោះស្រាយផ្លូវច្បាប់រដ្ឋបាលដែលមានក្រោមច្បាប់* IDEA *(គឺថា, បណ្តឹងត្រឹមត្រូវតាមច្បាប់, ការប្រជុំរកដំណោះស្រាយ, និងនីតិវិធីសវនាការត្រឹមត្រូវតាមច្បាប់មិនលំអៀង)សិន មុននឹងឈានចូលតុលាការដោយផ្ទាល់ ។*

# ការដាក់កុមារក្នុងសាលានៅពេលដែលសវនាការនិងបណ្ដឹងត្រឹមត្រូវតាមច្បាប់មិនទាន់សំរេច

## 34 CFR §300.518

លើកលែងតែដូចបានផ្ដល់ជូនខាងក្រោម ក្រោមជំពូក ***នីតិវិធីពេលដាក់វិន័យកុមារមានពិការភាព***, នៅពេលដែលបណ្ដឹងត្រឹមត្រូវតាមច្បាប់ត្រូវបញ្ជូនទៅឲ្យភាគីម្ខាងទៀតភ្លាម, ក្នុងកំឡុងពេលដំណើរការរកដំណោះស្រាយ, និងពេលកំពុងរង់ចាំសេចក្ដីសំរេចនៃសវនាការត្រឹមត្រូវតាមច្បាប់ដោយមិនលំអៀងឬនីតិវិធីតុលាការណាមួយ, លើកលែងតែអ្នកនិងរដ្ឋឬមណ្ឌលអប់រំព្រមព្រៀងផ្សេងពីនេះ, កូនអ្នកត្រូវស្ថិតនៅក្នុងគ្រឹះស្ថានសិក្សាបច្ចុប្បន្នរបស់វា ។

ប្រសិនបើបណ្ដឹងត្រឹមត្រូវតាមច្បាប់មានទាក់ទិននឹងពាក្យសុំចូលរៀនសាលារដ្ឋលើកដំបូង, កូនអ្នក, ដោយមានការយល់ព្រមពីអ្នក, ត្រូវតែដាក់ឲ្យរៀនក្នុងកម្មវិធីសិក្សារដ្ឋធម្មតា រហូតដល់ទីបញ្ចប់នៃនីតិវិធីទាំងនេះ ។

ប្រសិនបើបណ្ដឹងត្រឹមត្រូវតាមច្បាប់មានទាក់ទិននឹងពាក្យសុំសេវាដំបូងៗ ក្រោមផ្នែក B នៃច្បាប់ IDEA សំរាប់កុមារម្នាក់ដែលកំពុងប្ដូរពីការទទួលសេវាក្រោមផ្នែក C នៃច្បាប់ IDEA មកផ្នែក B នៃច្បាប់ IDEA ហើយដែលមិនមានសិទ្ធិទទួលសេវាផ្នែក C តទៅទៀតដោយកុមារនោះមានអាយុគ្រប់បីឆ្នាំ, នោះមណ្ឌលអប់រំមិនតម្រូវឲ្យផ្ដល់សេវាផ្នែក C ដែលកុមារនោះបានកំពុងទទួលទៀតឡើយ ។ ប្រសិនបើកុមារនោះត្រូវគេរកឃើញថាមានសិទ្ធិក្រោមផ្នែក B នៃច្បាប់ IDEA ហើយអ្នកយល់ព្រមឲ្យកុមារនោះទទួលសេវាសិក្សាអប់រំពិសេសនិងសេវាទាក់ទិនដទៃទៀតជាលើកដំបូង, នោះមណ្ឌលអប់រំត្រូវតែផ្ដល់សេវាសិក្សាអប់រំនិងសេវាទាក់ទិនទាំងនោះដែលមិនស្ថិតក្នុងជម្លោះ (សេវាទាំងឡាយដែលអ្នកនិងមណ្ឌលអប់រំទាំងពីរភាគីព្រមព្រៀង), រង់ចាំលទ្ធផលនៃនីតិវិធីទាំងនោះ ។

ប្រសិនបើមន្ត្រីសវនាការម្នាក់នៅក្នុងសវនាការបណ្ដឹងត្រឹមត្រូវតាមច្បាប់ដែលរៀបចំឡើងដោយភ្នាក់អប់រំរបស់រដ្ឋ (SEA) យល់ព្រមជាមួយនឹងអ្នកថា ការផ្លាស់ប្ដូរការកន្លែងគឺសមស្របនោះ កន្លែងនេះត្រូវតែចាត់ទុកជាកន្លែងអប់រំបច្ចុប្បន្នរបស់កូនរបស់អ្នក ជាទីដែលកូនរបស់អ្នកនឹងស្ថិតនៅខណៈពេលដែលរង់ចាំសេចក្ដីសម្រេចពីសវនាការបណ្ដឹងត្រឹមត្រូវតាមច្បាប់ ឬដំណើរការតាមនីតិវិធីរបស់តុលាការ។

# ថ្លៃឈ្នួលមេធាវី

## 34 CFR §300.517

***ទូទៅ***

ក្នុងបណ្ដឹងឬនីតិវិធីណាមួយ ប្ដឹងក្រោមផ្នែក B នៃច្បាប់ IDEA, ប្រសិនបើអ្នកឈ្នះ, តុលាការ, ក្នុងការសំរេចរបស់ខ្លួន, អាចដាក់ថ្លៃឈ្នួលមេធាវីសមស្រប ជាផ្នែកមួយនៃចំណាយរបស់អ្នក ។

ក្នុងបណ្ដឹងឬនីតិវិធីណាមួយ ប្ដឹងក្រោមផ្នែក B នៃច្បាប់ IDEA, តុលាការ, ក្នុងការសំរេចរបស់ខ្លួន, អាចដាក់ថ្លៃឈ្នួលមេធាវីសមស្រប ជាផ្នែកមួយនៃចំណាយ របស់ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំដែលជាអ្នកឈ្នះ, ដើម្បីចេញដោយមេធាវីរបស់អ្នក, ប្រសិនបើមេធាវីនោះ: (a) បានដាក់បណ្ដឹងឬករណីតុលាការ ដែលតុលាការរកឃើញថា គ្មានខ្លឹមសារ, មិនសមហេតុផល, ឬគ្មានមូលដ្ឋាន; ***ឬ*** (b) បាននៅតែបន្តប្ដឹង ក្រោយពេលបណ្ដឹងនោះបានក្លាយទៅជាគ្មានខ្លឹមសារ, មិនសមហេតុផល, ឬគ្មានមូលដ្ឋាន យ៉ាងច្បាស់ក្រឡែតហើយក៏ដោយ; ***ឬ***

ក្នុងបណ្ដឹងឬនីតិវិធីណាមួយ ប្ដឹងក្រោមផ្នែក B នៃច្បាប់ IDEA, តុលាការ, ក្នុងការសំរេចរបស់ខ្លួន, អាចដាក់ថ្លៃឈ្នួលមេធាវីសមស្រប ជាផ្នែកមួយនៃចំណាយរបស់ទីភ្នាក់ងារឬមណ្ឌអប់រំដែលជាអ្នកឈ្នះ, ដើម្បីចេញដោយអ្នក ឬមេធាវីអ្នក, ប្រសិនបើការស្នើសុំរបស់អ្នកឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់ ឬករណីតុលាការក្រោយមកទៀត ត្រូវបានដាក់ដោយចេតនាមិនសមរម្យណាមួយ, ដូចជាដើម្បីរំខាន, ដើម្បីឲ្យមានការពន្យារដោយមិនចាំបាច់, ឬដើម្បីធ្វើឲ្យចំណាយនៃបណ្ដឹងឬនីតិវិធីនោះកើតឡើងដោយមិនចាំបាច់ ។

### ការបែងចែកថ្លៃឈ្នួល

តុលាការបែងចែកថ្លៃឈ្នួលមេធាវី ដូចតទៅ:

1. ថ្លៃឈ្នួលត្រូវគិតតាមតំលៃដែលមានក្នុងសហគមន៍ ដែលបណ្ដឹងឬដំណើរការនោះកើតឡើង តាមប្រភេទនិងគុណភាព នៃសេវាកម្ម ដែលផ្ដល់ជូន ។ មិនអាចប្រើមេគុណឬប្រាក់លើកទឹកចិត្តឡើយ ក្នុងការទូទាត់ថ្លៃឈ្នួល ។
2. ថ្លៃឈ្នួលមិនអាចដាក់ឲ្យ ហើយចំណាយទាក់ទិនដទៃទៀនមិនអាចសងវិញបានឡើយ ក្នុងបណ្ដឹងឬនីតិវិធីណាមួយ ក្រោមផ្នែក B នៃច្បាប់ IDEA សំរាប់សេវាកម្មដែលផ្ដល់ជូន ក្រោយពេលសំណើរដំណោះស្រាយជាលយលក្ខណ៍អក្សរមួយត្រូវបានផ្ដល់ជូនអ្នក ប្រសិនបើ:
   a. សំណើនោះធ្វើឡើងក្នុងកំឡុងពេលចែងដោយបញ្ញត្តិលេខ 68 នៃច្បាប់សហព័ន្ធស្ដីពីនីតិវិធីរដ្ឋប្បវេណី ឬ, ក្នុងករណីសវនាការត្រឹមត្រូវតាមច្បាប់ ឬការពិនិត្យឡើងវិញថ្នាក់រដ្ឋ, នៅពេលណាមួយលើសពី 10 ថ្ងៃប្រក្រតិទិន មុនពេលនីតិវិធីចាប់ផ្ដើម;
   b. សំណើនោះមិនត្រូវបានទទួលក្នុងកំឡុងពេល 10 ថ្ងៃប្រក្រតិទិន; ***និង***
   c. មន្ត្រីតុលាការឬមន្ត្រីសវនាការរដ្ឋបាល រកឃើញថា ការជួសជុលដែលទីបំផុតទទួលបានដោយអ្នក មិនល្អជាងសំណើដំណោះស្រាយនោះឡើយ ។

   ទោះបីមានលក្ខខ័ណ្ឌទាំងនេះក៏ដោយ, ថ្លៃឈ្នួនមេធាវីនិងចំណាយទាក់ទិនដទៃទៀត អាចត្រូវដាក់ឲ្យអ្នក ប្រសិនបើអ្នកជាអ្នកឈ្នះ ហើយអ្នកត្រូវបានបង្ហាញនូវការសមហេតុសមផលយ៉ាងខ្លាំង ក្នុងការបដិសេធសំណើដំណោះស្រាយនោះ ។
3. មិនអាចឲ្យមានថ្លៃឈ្នួលទាក់ទិននឹងការប្រជុំណាមួយនៃក្រុមកម្មវិធីសិក្សាអប់រំសំរាប់បុគ្គល (IEP) លើកលែងតែការប្រជុំនោះធ្វើឡើងជាលទ្ធផលនៃនីតិវិធីរដ្ឋបាល ឬវិធានការតុលាការ ។

   ការប្រជុំរកដំណោះស្រាយមួយ, ដូចបានរៀបរាប់ក្រោមជំពូក ***ដំណោះស្រាយ***, សវនាការគឺមិនរាប់ថាជាការប្រជុំ កោះហៅជាលទ្ធផលនៃសវនាការរដ្ឋបាល ឬវិធានការតុលាការឡើយ, ហើយក៏មិនរាប់ថាជា សវនាការរដ្ឋបាល ឬវិធានការតុលាការដែរ ក្នុងបំណងនៃការផ្ដល់ថ្លៃឈ្នួលមេធាវីទាំងនេះ ។

តុលាការកាត់បន្ថយ, តាមសមគួរ, ចំនួនថ្លៃឈ្នួលមេធាវី ដែលដាក់ឲ្យក្រោមផ្នែក B នៃច្បាប់ IDEA, ប្រសិនបើតុលាការរកឃើញថា:

1. អ្នក, ឬមេធាវីអ្នក, ក្នុងកំឡុងពេលនៃបណ្ដឹងឬនីតិវិធី, ដោយមិនសមហេតុផល បានពន្យារដំណោះស្រាយចុងក្រោយនៃជម្លោះ;
2. ចំនួនថ្លៃឈ្នួលមេធាវី ដែលត្រូវអនុញ្ញាតឲ្យប្រគល់ឲ្យ លើសហួសហេតុអត្រាថ្លៃឈ្នួលម៉ោង ដែលមានស្រាប់ក្នុងសហគមន៍សំរាប់សេវាកម្មដូចគ្នានេះ ដោយមេធាវីដែលមានទេពកោសល, កេរ្តិ៍ឈ្មោះ, និងបទពិសោធន៍ប្រហាក់ប្រហែលគ្នា ។
3. ពេលវេលាដែលបានចំណាយ និងសេវាផ្នែកច្បាប់ដែលបានផ្ដល់ឲ្យ មានច្រើនហួស បើគិតអំពីចរិតនៃបណ្ដឹងឬនីតិវិធី; ***ឬ***
4. មេធាវីតំណាងឲ្យអ្នក មិនបានផ្ដល់មណ្ឌលអប់រំ នូវពត៌មានសមស្រប ក្នុងសេចក្ដីជូនដំណឹងស្ដីពីសំណើត្រឹមត្រូវតាមច្បាប់ ដូចបានរៀបរាប់ក្រោមជំពូក ***បណ្ដឹងត្រឹមត្រូវតាមច្បាប់*** ។

ប៉ុន្តែ, តុលាការមិនអាចកាត់បន្ថយថ្លៃឈ្នួលបានឡើយ ប្រសិនបើតុលាការរកឃើញថា រដ្ឋឬមណ្ឌលអប់រំ ដោយមិនសមហេតុផល បានពន្យារដំណោះស្រាយចុងក្រោយនៃបណ្ដឹងឬនីតិវិធី ឬមានការរំលោភអ្វីមួយ ក្រោមមាត្រានៃកិច្ចការពារតាមនីតិវិធីនៃផ្នែក B នៃច្បាប់ IDEA ។

# នីតិវិធីពេលដាក់វិន័យកុមារមានពិការភាព

## អំណាចបុគ្គលិកសាលា

## 34 CFR §300.530

### *ការកំណត់ករណីនីមួយៗដោយឡែកពីគ្នា*

*បុគ្គលិកសាលាអាចពិចារណាកាលៈទេសៈដែលមានតែមួយ ក្នុងមួយករណីម្តង, នៅពេលកំណត់ថាតើ ការប្តូរសាលា, ដែលធ្វើឡើងស្រប តាមតម្រូវការទាក់ទិននឹងវិន័យដូចខាងក្រោមនេះ, សមស្របសំរាប់កុមារមានពិការភាពម្នាក់ ដែលបានធ្វើខុសវិន័យសាលាណាមួយ ដែរឬ យ៉ាងណា ។*

### *ទូទៅ*

*ដូចគ្នានឹងការដែលគេក៏ចាត់វិធានការដូច្នេះដែរសំរាប់កុមារគ្មានពិការភាពនោះ, បុគ្គលិកសាលាអាច, ដោយមិនឲ្យលើសពី* ***10 ថ្ងៃរៀន ជាប់ៗគ្នា,*** *ដកកុមារមានពិការភាពម្នាក់ ដែលបានធ្វើខុសវិន័យសាលា ចេញពីថ្នាក់រៀនរបស់វាបច្ចុប្បន្ន ទៅដាក់ថ្នាក់រៀនមួយផ្សេងទៀតជាបណ្តោះអាសន្ន , ឬត្រូវបញ្ឈប់រៀន ។ បុគ្គលិកសាលាក៏អាចដកកុមារ នោះចេញ មិនលើសពី* ***10 ថ្ងៃរៀនជាប់ៗគ្នា*** *បន្ថែមទៀត ក្នុងឆ្នាំសិក្សាដដែលនេះ ដោយការប្រព្រឹត្តិខុសវិន័យផ្សេងពីគ្នា, ដរាបណាតែការ ដកចេញទាំងនោះមិនជាចំណែកនៃការប្តូរសាលា (សូមមើលនិយមន័យ* ***ការផ្លាស់ប្តូរសាលាដោយមូលហេតុត្រូវដកចេញដោយខុសវិន័យ****, ខាងក្រោម) ។*

*នៅពេលដែលកុមារមានពិការភាពម្នាក់ត្រូវបានដកចេញពីថ្នាក់រៀនបច្ចុប្បន្នរបស់វា រយៈពេលសរុប* ***10 ថ្ងៃរៀន*** *ក្នុងឆ្នាំសិក្សាដដែលនេះ ភ្លាម, មណ្ឌលអប់រំត្រូវ, ក្នុងកំឡុងថ្ងៃបន្តបន្ទាប់នៃការដកចេញក្នុងឆ្នាំសិក្សានោះ, ផ្តល់សេវាកម្មនានា ឲ្យដល់កម្រិតដូចតម្រូវឲ្យមានខាងក្រោមនេះ ក្រោមជំពូករង* ***សេវាកម្មនានា*** *។*

### *អំណាចបន្ថែមទៀត*

*ប្រសិនបើអាកប្បកិរិយាដែលរំលោភវិន័យសិស្សនោះ មិនមែនជាការបង្ហាញនូវពិការភាពរបស់កុមារនោះទេ (សូមមើល* ***ការកំណត់ការបង្ហាញឲ្យឃើញពិការភាព*** *ខាងក្រោម) ហើយការផ្លាស់កន្លែងរៀនដោយសារវិន័យ នឹងលើស* ***10 ថ្ងៃរៀន*** *ជាប់ៗគ្នា, បុគ្គលិកសាលាអាចអនុវត្ត នីតិវិធីវិន័យចំពោះកុមារមានពិការភាពនោះ ក្នុងរបៀបដូចគ្នា និងសំរាប់រយៈពេលដូចគ្នា ដូចដែលខ្លួននឹងដាក់ចំពោះកុមារដែលគ្មានពិការភាពដូច្នោះដែរ, គ្រាន់តែថា សាលាត្រូវផ្តល់សេវាកម្មនានាដល់កុមារនោះ ដូចរៀបរាប់ខាងក្រោមនេះ ក្រោមផ្នែក* ***សេវាកម្មនានា*** *។*

### *សេវាកម្មនានា*

*សេវាកម្មនានាដែលត្រូវផ្តល់ឲ្យកុមារមានពិការភាពម្នាក់ ដែលបានត្រូវគេដកចេញពីថ្នាក់រៀនបច្ចុប្បន្នរបស់វា អាចត្រូវផ្តល់ឲ្យក្នុងរូបភាពកន្លែងសិក្សាអប់រំផ្សេងមួយ ជាបណ្តោះអាសន្ន ។*

*មណ្ឌលអប់រំគ្រាន់តែត្រូវផ្តល់សេវាកម្មឲ្យកុមារមានពិការភាពម្នាក់ ដែលត្រូវបានគេដកចេញពីថ្នាក់រៀនបច្ចុប្បន្នរបស់វាអស់រយៈពេល* ***10 ថ្ងៃរៀន ឬតិចជាងនេះ*** *ក្នុងឆ្នាំសិក្សានោះ, ប្រសិនបើខ្លួនផ្តល់សេវាកម្មដល់កុមារគ្មានពិការភាព ដែលត្រូវបានគេដកចេញប្រហាក់ប្រហែលគ្នាដែរនោះ ។*

***កុមារមានពិការភាពម្នាក់ ដែលត្រូវដកចេញពីថ្នាក់រៀនបច្ចុប្បន្នរបស់វា*** *លើសពី 10 ថ្ងៃរៀន និងចរិយាមិនសំដែងអោយឃើញជាកុមារពិការ(សូមមើល ជំពូករង,* ***ការកំណត់ការបង្ហាញឲ្យឃើញពិការភាព****) រឺ អ្នកដែលត្រូវបានដកចេញក្រោម កាលៈទេសៈពិសេស (សូមមើលជំពូករង,* ***កាលៈទេសៈ ពិសេស****) ត្រូវតែ:*

1. *បន្តទទួលសេវាកម្មសិក្សាអប់រំ(ទទួលនូវការសិក្សាអប់រំសាធារណសមរម្យដោយឥតគិតថ្លៃ), ដើម្បីឲ្យកុមារនោះបន្តចូលរួមក្នុងកម្មវិធីសិក្សាទូទៅ, ទោះបីជាក្នុងកន្លែងផ្សេងមួយទៀតក៏ដោយ(ដែលអាចជាជំរើសការអប់រំបណ្តោះអាសន្នមួយ), និងដើម្បីឲ្យវាឈានទៅរកគោលដៅដែលបានដាក់ក្នុង IEP របស់វា;* ***និង***
2. *ទទួល, តាមការសមស្រប, ការប៉ាន់ស្មានពីចរិតអាកប្បកិរិយាមួយ, និងសេវាកម្មអន្តរាគមន៍អាកប្បកិរិយានិងការកែសំរួលនានា, ដែលបានរៀបចំឡើងសំរាប់ដោះស្រាយការរំលោភផ្នែកអាកប្បកិរិយា ដើម្បីកុំឲ្យកើតឡើងជាថ្មីទៀត ។*

*បន្ទាប់ពីកុមារមានពិការភាពម្នាក់ត្រូវបានគេដកចេញពីថ្នាក់រៀនបច្ចុប្បន្ន អស់រយៈពេល* ***10 ថ្ងៃរៀន*** *ក្នុងឆ្នាំសិក្សាដដែលនោះរួចមក, ហើយ****ប្រសិនបើ*** *ការដកចេញពេលនេះគឺសំរាប់រយៈពេល* ***10 ថ្ងៃរៀន****ជាប់ៗគ្នាឬតិចជាងនេះ* ***និង****ប្រសិនបើការដកចេញនោះមិនមែនជាការប្តូរកន្លែងរៀនទេនោះ (សូមមើល និយមន័យខាងក្រោម),* ***នោះ*** *បុគ្គលិកសាលា, ដោយមានការប្រឹក្សាយ៉ាងតិចជាមួយគ្រូម្នាក់របស់កុមារ, កំណត់កម្រិតដែលត្រូវការសេវាកម្ម ដើម្បីឲ្យកុមារអាចបន្តចូលរួមក្នុងកម្មវិធីសិក្សាទូទៅ, បើទោះជាក្នុងកន្លែងផ្សេងមួយទៀតក៏ដោយ, និងដើម្បីឲ្យកុមារអាចឈានទៅរកគោលដៅដែលបានដាក់ក្នុង IEP របស់វា ។*

*ប្រសិនបើការដកចេញនោះជាការប្តូរកន្លែងរៀន (សូមមើល ជំពូក,* ***ការប្តូរសាលាដោយមូលហេតុត្រូវដកចេញដោយសារខុសវិន័យ****), នោះក្រុម IEP របស់កុមារ ជាអ្នកកំណត់សេវាកម្ម សមស្របនានា ដើម្បីឲ្យកុមារអាចបន្តចូលរួមក្នុងកម្មវិធីសិក្សាទូទៅ, បើទោះជាក្នុងកន្លែងផ្សេងមួយទៀតក៏ដោយ (ដែលអាចជាជំរើសការអប់រំ បណ្តោះអាសន្នមួយ), និង ដើម្បីឲ្យកុមារអាចឈានទៅរកគោលដៅដែលបានដាក់ក្នុង IEP របស់វា ។*

### ការកំណត់ការបង្ហាញឲ្យឃើញពិការភាព

*ក្នុងរយៈពេល* ***10 ថ្ងៃរៀន*** *នៃសេចក្តីសំរេចឲ្យប្តូរកន្លែងរៀនរបស់កុមារមានពិការភាពម្នាក់ ដោយមកពីការរំលោភវិន័យ (លើកលែងតែសំរាប់ការដកចេញ ដែលមានរយៈពេល* ***10 ថ្ងៃរៀន*** *ជាប់ៗគ្នា និងមិនមែនជាការប្តូរកន្លែងរៀន), មណ្ឌលអប់រំ, អ្នក, និងសមាជិកពាក់ព័ន្ធដទៃនៃក្រុម IEP (ដូចបានកំណត់ដោយអ្នក និងមណ្ឌលអប់រំនោះ) ត្រូវពិនិត្យពត៌មានពាក់ព័ន្ធទាំងអស់ក្នុងសំណុំរឿងរបស់កុមារឲ្យបានហ្មត់ចត់ឡើងវិញ, រួមទាំង IEP របស់កុមារ, ការសង្កេតរបស់គ្រូ, និងពត៌មានពាក់ព័ន្ធណាមួយដែលផ្តល់ឲ្យដោយអ្នកដើម្បីកំណត់:*

1. *ថាតើ អាកប្បកិរិយាដែលមានបញ្ហានោះ បណ្តាលមកពី, ឬមានទំនាក់ទំនងផ្ទាល់និងខ្លាំងក្លា, នឹងពិការភាពរបស់កុមារនោះ;* ***ឬ***
2. *ថាតើ អាកប្បកិរិយាដែលមានបញ្ហានោះ ជាលទ្ធផលផ្ទាល់នៃការបរាជ័យរបស់មណ្ឌលអប់រំ ក្នុងការអនុវត្តន៍IEP របស់កុមារ ឬយ៉ាងណា ។*

*ប្រសិនបើមណ្ឌលអប់រំ, អ្នក, និងសមាជិកពាក់ព័ន្ធនៃក្រុម IEP របស់កុមារ កំណត់ថា មិនត្រូវនឹងលក្ខខ័ណ្ឌណាមួយនៃលក្ខខ័ណ្ឌទាំងពីរខាងលើនោះទេ, នោះអាកប្បកិរិយានោះត្រូវតែកំណត់ថា ជាការបង្ហាញឲ្យឃើញពិការភាពរបស់កុមារនោះ ។*

*ប្រសិនបើមណ្ឌលអប់រំ, អ្នក, និងសមាជិកពាក់ព័ន្ធនៃក្រុម IEP របស់កុមារ កំណត់ថា អាកប្បកិរិយាមានបញ្ហានោះជាលទ្ធផល ផ្ទាល់នៃការបរាជ័យរបស់មណ្ឌលអប់រំក្នុងការអនុវត្តន៍ IEP, នោះមណ្ឌលអប់រំត្រូវចាត់វិធានការភ្លាមៗ ដើម្បីដោះស្រាយកង្វះខាត ទាំងនោះ។*

### *ការកំណត់ថា អាកប្បកិរិយាមួយគឺជាការបង្ហាញឲ្យឃើញពិការភាពរបស់កុមារ*

*ប្រសិនបើមណ្ឌលអប់រំ, អ្នក, និងសមាជិកពាក់ព័ន្ធនៃក្រុម IEP របស់កុមារ កំណត់ថា អាកប្បកិរិយានោះគឺជាការបង្ហាញឲ្យឃើញពិការភាពរបស់កុមារ, នោះក្រុម IEP ឬមួយ:*

1. *ត្រូវធ្វើការប៉ាន់ស្មានចរិតអាកប្បកិរិយាមួយ, លើកលែងតែមណ្ឌលអប់រំបានធ្វើការប៉ាន់ស្មានចរិតអាកប្បកិរិយាមួយរួចហើយ មុនពេលដែលអាកប្បកិរិយាដែលបណ្តាលឲ្យមានការប្តូរកន្លែងរៀននោះបានកើតឡើង, និងអនុវត្តគំរោងអន្តរាគមន៍ផ្នែកអាកប្បកិរិយាមួយ សំរាប់កុមារ; ឬមួយ*
2. *ប្រសិនបើគំរោងអន្តរាគមន៍ផ្នែកអាកប្បកិរិយាមួយត្រូវបានបង្កើតរួចហើយ, ត្រូវពិនិត្យគំរោងអន្តរាគមន៍ផ្នែកអាកប្បកិរិយានោះឡើងវិញឲ្យបានហ្មត់ចត់, កែសំរួលវា, តាមការចាំបាច់, ដើម្បីដោះស្រាយអាកប្បកិរិយានោះ ។*

*លើកលែងតែដូចរៀបរាប់ខាងក្រោមនេះ ក្រោមជំពូករង **កាលៈទេសៈពិសេស**, មណ្ឌលអប់រំត្រូវបញ្ជូនកុមារត្រឡប់ទៅកន្លែងរៀនដែលកុមារនោះត្រូវបានដកចេញ, លើកលែងតែ អ្នក និង មណ្ឌលអប់រំព្រមព្រៀងឲ្យមានការប្តូរកន្លែងរៀនជាផ្នែកមួយនៃការកែសំរួលគំរោងអន្តរាគមន៍ផ្នែកអាកប្បកិរិយា ។*

### *កាលៈទេសៈពិសេស*

*ទោះជាអាកប្បកិរិយានោះជាការបង្ហាញឲ្យឃើញពិការភាពរបស់កុមារឬមិនមែនក៏ដោយ, បុគ្គលិកសាលាអាចដកសិស្សម្នាក់ចេញ ទៅដាក់កន្លែងរៀនផ្សេងមួយទៀតបណ្តោះអាសន្ន (កំណត់ដោយក្រុម IEP របស់កុមារ) សំរាប់រយៈពេលរហូតដល់ 45 ថ្ងៃរៀន, បើសិនជាកុមារនោះ:*

1. *យកអាវុធ (សូមមើលនិយមន័យខាងក្រោម) មកសាលា ឬមានអាវុធនៅសាលា, ក្នុងទីធ្លាសាលា, ឬនៅឯកម្មវិធីសាលាមួយក្រោមដែនសមត្ថកិច្ចរបស់ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំ;*
2. *ដឹងខ្លួនថាមានឬប្រើគ្រឿងញៀនខុសច្បាប់ (សូមមើលនិយមន័យខាងក្រោម), ឬលក់ ឬជួរលក់សារធាតុស្ថិតក្រោមការគ្រប់គ្រង (សូមមើលនិយមន័យខាងក្រោម), ពេលនៅសាលា, ក្នុងទីធ្លាសាលា, ឬនៅឯកម្មវិធីសាលាមួយក្រោមដែនសមត្ថកិច្ចរបស់ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំមួយ; ឬ*
3. *បានបង្កឲ្យមានរបួសស្នាមរាងកាយធ្ងន់ធ្ងរ (សូមមើលនិយមន័យខាងក្រោម) ទៅលើបុគ្គលម្នាក់ទៀត ពេលនៅសាលា, ក្នុងទីធ្លាសាលា, ឬនៅឯកម្មវិធីសាលាមួយក្រោមដែនសមត្ថកិច្ច របស់ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំមួយ ។*

### *និយមន័យ*

*សារធាតុដែលគេគ្រប់គ្រង* មានន័យថា ជាថ្នាំញៀនឬសារធាតុផ្សេងទៀត សំគាល់អត្តសញ្ញាណក្រោមមាត្រា I, II, III, IV, ឬ V ក្នុងផ្នែក 202(c) នៃច្បាប់ស្តីពីសារធាតុដែលគេគ្រប់គ្រង (21 U.S.C. 812(c)) ។

*ថ្នាំញៀនខុសច្បាប់* មានន័យថា ជាសារធាតុដែលគេគ្រប់គ្រងមួយ; ប៉ុន្តែមិនរាប់បញ្ចូលសារធាតុដែលគេគ្រប់គ្រងណាដែលមានជាកម្មសិទ្ធិស្របច្បាប់ ឬប្រើប្រាស់ក្រោមការឃ្លាំមើលពីអ្នកជំនាញផ្នែកក្សុខភាពដែលមានអាជ្ញាប័ណ្ណ ឬ ដែលមានជាកម្មសិទ្ធិស្របច្បាប់ឬប្រើប្រាស់ក្រោមសិទ្ធិអំណាចផ្សេងទៀត ក្រោមច្បាប់នោះ ឬក្រោមមាត្រាណាមួយផ្សេងទៀតនៃច្បាប់សហព័ន្ធឡើយ ។

*របួសស្នាមរាងកាយធ្ងន់ធ្ងរ* មានអត្ថន័យដូចពាក្យ "របួសស្នាមរាងកាយធ្ងន់ធ្ងរ" ក្រោមកថាខ័ណ្ឌ (3) នៃផ្នែករង (h) នៃផ្នែក 1365 នៃ Title 18, ក្រមសហរដ្ឋអាមេរិក ។

*អាវុធ* មានអត្ថន័យដូចពាក្យ "អាវុធមានគ្រោះថ្នាក់" ក្រោមកថាខ័ណ្ឌ (2) នៃផ្នែករងទីមួយ (g) នៃផ្នែក 930 នៃ Title 18, ក្រមសហរដ្ឋអាមេរិក ។

### *ការជូនដំណឹង*

*នៅថ្ងៃដែលខ្លួនធ្វើសេចក្តីសំរេចដកចេញ ដែលជាការប្តូរកន្លែងរៀន ដោយមកពីការរំលោភវិន័យសិស្សសាលា, មណ្ឌលអប់រំត្រូវជូនដំណឹងទៅ អ្នក អំពីសេចក្តីសំរេចនោះ, ព្រមទាំងផ្តល់ឲ្យអ្នក នូវសេចក្តីជូនដំណឹងមួយស្តីពីកិច្ចការពារតាមនីតិវិធី ។*

# ការផ្លាស់ប្ដូរសាលាដោយមូលហេតុត្រូវដកចេញដោយសារខុសវិន័យ

## 34 CFR §300.536

*ការដកកូនអ្នក ដែលមានពិការភាពចេញពីកន្លែងរៀនបច្ចុប្បន្នរបស់កូនអ្នក ចាត់ទុកថាជា**ការប្ដូរកន្លែងរៀន** ប្រសិនបើៈ*

1. *ការដកចេញនោះគឺសំរាប់រយៈពេលលើសពី 10 ថ្ងៃរៀន ជាប់ៗគ្នា; **ឬ***
2. *កូនអ្នកបានរងនូវការដកចេញច្រើនលើកច្រើនសារ ដែលក្លាយជាទំលាប់មួយ ដោយសារៈ*
   a. *ការដកចេញច្រើនលើកច្រើនសារនោះ មានរយៈពេលសរុបលើសពី 10 ថ្ងៃរៀន ក្នុងមួយឆ្នាំសិក្សា;*
   b. *អាកប្បកិរិយារបស់កូនអ្នកប្រហាក់ប្រហែលគ្នាច្រើន ទៅនឹងអាកប្បកិរិយារបស់វាក្នុងហេតុការណ៍មុនៗ ដែលនាំឲ្យមានការដកចេញច្រើនលើកច្រើនសារនេះ;*
   c. *មានកត្តានានាបន្ថែមទៀតដូចជា រយៈពេលនៃការដកចេញម្ដងៗ, រយៈពេលសរុបដែលកុមារនោះត្រូវបានដកចេញ, និងចន្លោះពេលរវាងពីការដកចេញមួយទៅការដកចេញមួយទៀតៗ*

*តើទំលាប់នៃការដកចេញ បានជាផ្នែកមួយនៃការប្ដូរកន្លែងរៀនឬយ៉ាងណា គឺកំណត់ដោយមណ្ឌលអប់រំ មួយករណីៗដាច់ពីគ្នា ហើយ, ប្រសិនបើមានការតវ៉ា, អាចនឹងត្រូវពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ដោយនីតិវិធីត្រឹមត្រូវតាមច្បាប់និងតុលាការ ។*

# ការកំណត់កន្លែងរៀន

## 34 CFR § 300.531

*ក្រុមកម្មវិធីសិក្សាអប់រំសំរាប់បុគ្គល (IEP) កំណត់កន្លែងសិក្សាអប់រំផ្សេងមួយបណ្ដោះអាសន្ន សំរាប់សិស្សត្រូវគេដកចេញ ដែលជា**ការប្ដូរកន្លែងរៀន**, និងសិស្សដែលត្រូវគេដកចេញ ក្រោមជំពូករង **អំណាចបន្ថែម** និង **កាលៈទេសៈពិសេស** ។*

# បណ្ដឹងឧទ្ធរណ៍

## 34 CFR § 300.532

***ទូទៅ***

*អ្នកអាចដាក់បណ្ដឹងត្រឹមត្រូវតាមច្បាប់ (សូមមើលជំពូក **និតិវិធីបណ្ដឹងត្រឹមត្រូវតាមច្បាប់**) មួយដើម្បីស្នើសុំឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់មួយ ប្រសិនបើអ្នកមិនយល់ស្របនឹងៈ*

1. *សេចក្ដីសំរេចណាមួយ ពាក់ព័ន្ធនឹងការដាក់កន្លែងរៀន ក្រោមមាត្រាវិន័យទាំងនេះ; **ឬ***
2. *ការកំណត់ការបង្ហាញឲ្យឃើញពិការភាព ដូចរៀបរាប់ខាងលើ ។*

*មណ្ឌលអប់រំអាចដាក់បណ្ដឹងត្រឹមត្រូវតាមច្បាប់ (សូមមើលខាងលើ) ដើម្បីស្នើសុំឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់មួយ ប្រសិនបើខ្លួនជឿជាក់ថា ការរក្សាទុកកន្លែងរៀនបច្ចុប្បន្នរបស់កុមារ គង់នឹងអាចបណ្ដាលឲ្យមានរបួសស្នាមដល់កុមារនោះ ឬអ្នកដទៃ ។*

***អំណាចរបស់មន្ត្រីសវនាការ***

*មន្ត្រីសវនាការម្នាក់ ដែលឆ្លើយតបទៅនឹងតម្រូវការដូចរៀបរាប់ក្នុងផ្នែករង **មន្ត្រីសវនាការមិនលំអៀង** ខាងលើ ត្រូវតែធ្វើសវនាការត្រឹមត្រូវតាមច្បាប់នោះ ហើយត្រូវធ្វើសេចក្តីសំរេចមួយ ។ មន្ត្រីសវនាការនោះ អាចៈ*

1. *បញ្ជូនកូនអ្នកដែលមានពិការភាពនោះត្រឡប់ទៅកន្លែងរៀនដែលកូនអ្នកត្រូវបានគេដកចេញ ប្រសិនបើមន្ត្រីសវនាការកំណត់ថា ការដក ចេញ គឺជាការរំលោភលក្ខខ័ណ្ឌដែលបានរៀបរាប់ក្រោមជំពូក **អំណាចបុគ្គលិកសាលា**, ឬថា អាកប្បកិរិយារបស់កូនអ្នកនោះ គឺជាការបង្ហាញឲ្យឃើញពិការភាពរបស់កូនអ្នក; **<u>ឬ</u>***
2. *បញ្ជារឲ្យប្តូរកន្លែងរៀនរបស់កូនអ្នកដែលមានពិការភាពនោះ ទៅកន្លែងរៀនមួយទៀតបណ្តោះអាសន្នសមស្រប សំរាប់មិនលើសពី 45 ថ្ងៃរៀន ប្រសិនបើមន្ត្រីសវនាការកំណត់ថា ការរក្សាទុកកន្លែងរៀនបច្ចុប្បន្នរបស់កូនអ្នកគង់នឹងបណ្តាលឲ្យមានរបួសស្នាមដល់ កូនអ្នកខ្លួនឯង ឬអ្នកដទៃ ។*

*នីតិវិធីសវនាការទាំងនេះ អាចត្រូវអនុវត្តឡើងវិញ, ប្រសិនបើមណ្ឌលអប់រំជឿជាក់ថា ការបញ្ជូនកូនអ្នកត្រឡប់ទៅកន្លែងរៀនដើមវិញ គង់នឹងបណ្តាលឲ្យមានរបួសស្នាមដល់កូនអ្នក ឬអ្នកដទៃ ។*

*នៅពេលណាក៏ដោយដែលអ្នក ឬមណ្ឌលអប់រំ ដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់ ដើម្បីស្នើសុំឲ្យមានសវនាការបែបនេះ, សវនាការមួយត្រូវតែធ្វើឡើង ឲ្យឆ្លើយតបទៅនឹងតម្រូវការដូចរៀបរាប់ក្រោមជំពូក **នីតិវិធីបណ្តឹងត្រឹមត្រូវតាមច្បាប់, សវនាការលើបណ្តឹងត្រឹមត្រូវតាមច្បាប់**, លើកលែងតែដូចខាងក្រោមៈ*

1. *ទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំ ត្រូវរៀបចំឲ្យមានសវនាការត្រឹមត្រូវតាមច្បាប់ឲ្យបានរួសរាន់មួយ, ដែលត្រូវតែកើតមានឡើងក្នុងរយៈពេល* **<u>20</u>** *ថ្ងៃរៀន នៃថ្ងៃដែលសវនាការនោះត្រូវបានស្នើឡើង ហើយត្រូវឲ្យមានការកំណត់មួយក្នុងរយៈពេល* **<u>10</u>** *ថ្ងៃរៀន ក្រោយសវនាការនោះ ។*
2. *លើលែងតែ អ្នក និងមណ្ឌលអប់រំ ព្រមព្រៀងថាមិនចាំបាច់មានការប្រជុំ, ឬព្រមព្រៀងថាប្រើការសម្រុះសម្រួល, ការប្រជុំរកដំណោះស្រាយមួយត្រូវកើតមានឡើងក្នុងរយៈពេល **<u>ប្រាំពីរ</u>** ថ្ងៃប្រក្រតិទិន នៃការទទួលសេចក្តីជូនដំណឹងស្តីពីបណ្តឹងត្រឹមត្រូវតាមច្បាប់នោះ ។ សវនាការអាចធ្វើដំណើរទៅមុខបាន លើកលែងតែបញ្ហាបានត្រូវដោះស្រាយដោយភាគីទាំងពីរពេញចិត្តរួចហើយ ក្នុងរយៈពេល* **<u>15</u>** *ថ្ងៃប្រក្រតិទិន នៃការទទួលបណ្តឹងត្រឹមត្រូវតាមច្បាប់នោះ ។*
3. *រដ្ឋណាមួយ អាចបង្កើតបទបញ្ញត្តិនីតិវិធីសំរាប់សវនាការត្រឹមត្រូវតាមច្បាប់រួសរាន់ ខុសពីបទបញ្ញត្តិនីតិវិធីដែលខ្លួនបង្កើតសំរាប់សវនាការត្រឹមត្រូវតាមច្បាប់ផ្សេងទៀត, ប៉ុន្តែលើកលែងតែពេលវេលាកំណត់ចេញ, បទបញ្ញត្តិទាំងនោះត្រូវតែស្របទៅនឹងបទបញ្ញត្តិក្នុងឯកសារនេះពាក់ព័ន្ធនឹងសវនាការត្រឹមត្រូវតាមច្បាប់ ។*

*អ្នក រឺ មណ្ឌលអប់រំអាចប្តឹងតវ៉ាសេចក្តីសំរេចក្នុងសវនាការត្រឹមត្រូវតាមច្បាប់រួសរាន់ ដូចដែលគេអាចប្តឹងតវ៉ាសេចក្តីសំរេចក្នុងសវនាការត្រឹមត្រូវ តាមច្បាប់ដទៃទៀតដែរ (សូមមើល **បណ្តឹងឧទ្ធរណ៍**, ខាងលើ) ។*

# *ការដាក់កុមារក្នុងស្ថាប័នសិក្សាក្នុងពេលបណ្តឹងឧទ្ធរណ៍*

## 34 CFR §300.533

*ដូចបានរៀបរាប់ខាងលើ, នៅពេលដែលអ្នក ឬមណ្ឌលអប់រំបានដាក់បណ្តឹងត្រឹមត្រូវតាមច្បាប់មួយ ទាក់ទិននឹងបញ្ហាវិន័យ, កូនអ្នក ត្រូវ (លើកលែងតែអ្នក និងទីភ្នាក់ងារអប់រំរដ្ឋ ឬមណ្ឌលអប់រំ ព្រមព្រៀងផ្សេងពីនេះ) ស្ថិតក្នុងកន្លែងសិក្សាអប់រំមួយផ្សេងបណ្តោះ អាសន្នរង់ចាំសេចក្តីសំរេចរបស់មន្ត្រីសវនាការ, ឬរហូតដល់ការផុតកំណត់នៃរយៈពេលដកចេញ ដូចបានផ្តល់ឲ្យនិងរៀបរាប់ក្រោមជំពូក **អំណាចបុគ្គលិកសាលា**, ករណីណាមួយកើតឡើងមុនក៏បាន ។*

# ការការពារកុមារដែលមិនទាន់មានលក្ខណៈគ្រប់គ្រាន់ទទួលសេវាអប់រំពិសេស និងសេវាទាក់ទិនផ្សេងទៀត

## 34 CFR §300.534

### *ទូទៅ*

*ប្រសិនបើកូនអ្នកមិនទាន់ត្រូវបានគេកំណត់ថាមានលក្ខណៈគ្រប់គ្រាន់នឹងទទួលសេវាអប់រំពិសេសនិងសេវាទាក់ទិនផ្សេងទៀត ហើយបានរំលោភវិន័យសិស្ស, ប៉ុន្តែមណ្ឌលអប់រំដឹង (ដូចបានកំណត់ខាងក្រោមនេះ) មុនពេលអាកប្បកិរិយាដែលនាំមកនូវវិធានការដាក់វិន័យនោះកើតមានឡើង, ថាកូនអ្នកនោះជាកុមារមានពិការភាព, នោះកូនអ្នកអាចត្រូវទទួលការការពារដូចបានរៀបរាប់ក្នុងសេចក្តីជូនដំណឹង នេះ ។*

### *មូលដ្ឋាននៃការដឹងឮបញ្ហាវិន័យ*

*មណ្ឌលអប់រំនឹងចាត់ទុកថាមានការដឹងឮថា កូនអ្នកគឺជាកុមារមានពិការភាព ប្រសិនបើ, មុនអាកប្បកិរិយាដែលនាំមកនូវវិធនាការដក់វិន័យបានកើតឡើង:*

1. *អ្នក បានសំដែងការព្រួយបារម្ភជាលាយលក្ខណ៍អក្សរ ឲ្យបុគ្គលិករដ្ឋបាលឬគ្រប់គ្រងនៃទីភ្នាក់ងារអប់រំសមស្រប, ឬគ្រូរបស់កូនអ្នកថា កូនអ្នកត្រូវការសេវាអប់រំពិសេសនិងសេវាទាក់ ទិនផ្សេងទៀត;*
2. *អ្នកបានស្នើសុំឲ្យមានការវាយតំលៃទាក់ទិននឹងការកំណត់លក្ខណៈគ្រប់គ្រាន់សំរាប់ទទួលសេវាអប់រំពិសេសនិងសេវាទាក់ទិនផ្សេងទៀត ក្រោមផ្នែក* B *នៃច្បាប់* IDEA*; **ឬ***
3. *គ្រូរបស់កូនអ្នក, ឬបុគ្គលិកមណ្ឌលអប់រំផ្សេងទៀត បានសំដែងការព្រួយបារម្ភជាក់លាក់ អំពីអាកប្បកិរិយាជាទំលាប់មួយបង្ហាញដោយកុមារនោះ ដោយផ្ទាល់ដល់នាយកមណ្ឌលអប់រំទទួលបន្ទុកផ្នែកការសិក្សាអប់រំពិសេសឬបុគ្គលិកគ្រប់គ្រងផ្សេងទៀតនៃមណ្ឌលអប់រំនោះ ។*

### *ករណីលើកលែង*

*មណ្ឌលអប់រំមួយនឹងមិនត្រូវចាត់ទុកថាមានការដឹងឮដូច្នោះឡើយ ប្រសិនបើ:*

1. *អ្នក មិនបានអនុញ្ញាតឲ្យមានការវាយតំលៃមួយលើកុមារ ឬបានបដិសេធមិនឲ្យកូនទទួលសេវាអប់រំពិសេស; **ឬ***
2. *កូនអ្នកបានត្រូវវាយតំលៃនិងកំណត់រួចហើយថា មិនមែនជាកុមារមានពិការភាពឡើយ ក្រោមផ្នែក* B *នៃច្បាប់* IDEA *។*

### *លក្ខខ័ណ្ឌដែលត្រូវអនុវត្តប្រសិនបើគ្មានមូលដ្ឋាននៃការដឹងឮ*

*ប្រសិនបើមុនពេលចាត់វិធានការដាក់វិន័យលើកូនអ្នក, មណ្ឌលអប់រំពុំមានការដឹងឮថាកូនអ្នកជាកុមារមានពិការភាព, ដូចបានរៀបរាប់ខាងលើក្រោមជំពូករង **មូលដ្ឋាននៃការដឹងឮសំរាប់បញ្ហាវិន័យ** និង **ករណីលើកលែង** ទេនោះ, កូនអ្នកអាចនឹងទទួលការដាក់វិន័យដែលអនុវត្តចំពោះកុមារគ្មានពិការភាពទាំងឡាយ ដែលបានប្រព្រឹត្តិអាកប្បកិរិយាដូចគ្នានោះដែរ ។*

*ប៉ុន្តែ, ប្រសិនបើមានការស្នើសុំឲ្យមានការវាយតំលៃកូនអ្នកក្នុងពេលដែលកូនអ្នកអាចត្រូវទទួលការដាក់វិន័យ, ការវាយតំលៃនោះត្រូវធ្វើឡើង ឲ្យបានរួសរាន់បំផុត ។*

*រហូតដល់ការវាយតំលៃនោះបញ្ចប់, កូនអ្នកត្រូវស្ថិតក្នុងកន្លែងរៀនដែលកំណត់ដោយអាជ្ញាធមិសាលា, ដែលអាចរួមមានការព្យួរឬការបណ្តេញចេញដោយគ្មានសេវាអប់រំ ។*

*ប្រសិនបើកូនអ្នកត្រូវបានកំណត់ថាជាកុមារមានពិការភាព, ដោយយកមកពិចារណានូវពត៌មានពីការវាយតំលៃធ្វើឡើងដោយមណ្ឌលអប់រំ, និងពត៌មានផ្តល់ដោយអ្នក, មណ្ឌលអប់រំត្រូវផ្តល់សេវាអប់រំពិសេសនិងសេវាទាក់ទិនផ្សេងទៀត ស្របតាមផ្នែក* B *នៃច្បាប់* IDEA*, រួមទាំងលក្ខខ័ណ្ឌវិន័យដែលបានរៀបរាប់ខាងលើផង ។*

# ការបញ្ជូនទៅនិងវិធានការដោយរដ្ឋអំណាចពង្រឹងច្បាប់និងតុលាការ

## 34 CFR §300.535

*ផ្នែក B នៃច្បាប់ IDEA មិនៈ*

1. *ហាមឃាត់ទីភ្នាក់ងារណាមួយ ពីការរាយការណ៍អំពីបទល្មើសមួយប្រព្រឹត្តិឡើងដោយកុមារមានពិការភាពម្នាក់ ទៅឲ្យអាជ្ញាធមិសមស្របឡើយ; __ឬ__*
2. *រាំងរដ្ឋអំណាចពង្រឹងច្បាប់និងតុលាការ ពីការអនុវត្តន៍ការទទួលខុសត្រូវរបស់ខ្លួន ក្នុងការអនុវត្តន៍ច្បាប់រដ្ឋនិងច្បាប់សហព័ន្ធចំពោះបទល្មើសនានា ប្រព្រឹត្តិឡើងដោយកុមារមានពិការភាពម្នាក់ ឡើយ ។*

### ការបញ្ជូនឯកសារ

*ប្រសិនបើមណ្ឌលអប់រំមួយ រាយការណ៍បទល្មើសមួយដែលប្រព្រឹត្តិឡើងដោយកុមារមានពិការភាពម្នាក់, នោះមណ្ឌលអប់រំនោះៈ*

1. *ត្រូវធានាថា ច្បាប់ចំឡងនៃឯកសារទាក់ទិននឹងការដាក់វិន័យនិងការអប់រំពិសេសរបស់កុមារនោះ ត្រូវបញ្ជូនទៅរដ្ឋអំណាចដែលខ្លួនបានរាយការណ៍បទល្មើសនោះ ដើម្បីធ្វើការពិចារណា; __**និង**__*
2. *អាចបញ្ជូនច្បាប់ចំឡងនៃឯកសាទាក់ទិននឹងការដាក់វិន័យនិងការអប់រំពិសេសរបស់កុមារនោះ ត្រឹមតែកម្រិតដែលអនុញ្ញាតបានដោយច្បាប់ស្តីពីសិទ្ធិសិក្សាអប់រំគ្រួសារនិងភាពជាឯកជន ប៉ុណ្ណោះ ។*

# តម្រូវការនានាសំរាប់ការដាក់កូនឲ្យរៀនក្នុងសាលាឯកជនដោយចំណាយលុយរដ្ឋ ដោយមាតាបិតាជាឯកតោភាគី

# ទូទៅ

## 34 CFR §300.148

*ផ្នែក B នៃច្បាប់ IDEA មិនតម្រូវឲ្យមណ្ឌលអប់រំមួយបង់ចំណាយការសិក្សាអប់រំ, រួមទាំងសេវាអប់រំពិសេសនិងសេវាទាក់ទិនផ្សេងទៀតផង, សំរាប់កូនរបស់អ្នកដែលមានពិការភាព ក្នុងសាលាឬកន្លែងឯកជនឡើយ ប្រសិនបើមណ្ឌលអប់រំនោះបានរៀបចំឲ្យមានការសិក្សាអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) សំរាប់កូនអ្នក ហើយអ្នកជ្រើសរើសដាក់កូនអ្នកក្នុងសាលាឬកន្លែងឯកជននោះ ។ ប៉ុន្តែ, មណ្ឌលអប់រំដែលសាលាឯកជននោះមានទីតាំង ត្រូវតែរាប់បញ្ចូលកូនអ្នក ក្នុងចំណោមអ្នកដែលតម្រូវការរបស់ពួកគេត្រូវបានដោះស្រាយក្រោមមាត្រានានានៃផ្នែក B ទាក់ទិននឹងកុមារដែលបានត្រូវដាក់ដោយមាតាបិតារបស់ពួកគេ ឲ្យរៀនក្នុងសាលាឯកជនមួយក្រោមមាត្រា 34 CFR 300.131 រហូតដល់ 300.144 ។*

### សំណងការចំណាយក្នុងការដាក់កូនឲ្យរៀននៅសាលាឯកជន

*ប្រសិនបើកូនអ្នកកាលពីមុនបានទទួលសេវាអប់រំពិសេសនិងសេវទាក់ទិនផ្សេងទៀតក្រោមការគ្រប់គ្រងរបស់មណ្ឌលអប់រំមួយ, ហើយអ្នកជ្រើសរើសចុះឈ្មោះកូនឲ្យរៀននៅសាលាមត្តេយ្យ, សាលាបឋមសិក្សា, ឬសាលាមធ្យមសិក្សាឯកជន ដោយគ្មានការយល់ព្រមរបស់មណ្ឌលអប់រំនោះ ឬ ការបញ្ជូនដោយមណ្ឌលអប់រំនោះ, មន្ត្រីតុលាការឬសវនាការមួយអាចតម្រូវឲ្យទីភ្នាក់ងារនោះសងអ្នកវិញនូវចំណាយនៃការចូលរៀននោះ ប្រសិនបើមន្ត្រីតុលាការឬសវនាការនោះរកឃើញថា ទីភ្នាក់ងារនោះមិនបានរៀបចំឲ្យមានការសិក្សាអប់រំសាធារណៈសមស្របដោយឥតគិតថ្លៃ (FAPE) ដល់កូនអ្នក ឲ្យបានទាន់ពេលវេលា មុនពេលរៀននោះ និងថាការដាក់ឲ្យរៀននៅសាលាឯកជននោះ*

ជាការសមស្រប ។ មន្រ្តីសវនាការម្នាក់ ឬតុលាការ អាចរកឃើញថា ការដាក់កូនឲ្យរៀនរបស់អ្នកជាការសមស្រប, ទោះបីជាការដាក់នោះ មិនឆ្លើយតបទៅនឹងកម្រិតស្តង់ដាររដ្ឋដែលអនុវត្តចំពោះការសិក្សាអប់រំផ្តល់ដោយទីភ្នាក់ងារអប់រំរដ្ឋនិងមណ្ឌលអប់រំក៏ដោយ ។

**កម្រិតនៃការសង**

ចំណាយនៃការសងដូចរៀបរាប់ក្នុងកថាខ័ណ្ឌខាងលើអាចត្រូវកាត់បន្ថយឬបដិសេធ:

1. ប្រសិនបើ: (a) នៅឯការប្រជុំចុងក្រោយនៃកម្មវិធីសិក្សាអប់រំសំរាប់បុគ្គល ដែលអ្នកបានចូលរួមមុនពេលអ្នកដកកូនចេញពីសាលារដ្ឋ, អ្នកមិនបានឲ្យដំណឹងទៅក្រុម IEP ថាអ្នកបដិសេធការដាក់កន្លែងរៀន ដែលស្នើឡើងដោយមណ្ឌលអប់រំ ដើម្បីផ្តល់ FAPE ដល់កូនអ្នក, រួមទាំងអះអាងពីការព្រួយបារម្ភនិងគោលបំណងរបស់អ្នកក្នុងការចុះឈ្មោះកូនអ្នកឲ្យរៀននៅសាលាឯកជនដោយចំណាយលុយរដ្ឋ; ឬ (b) យ៉ាងតិច 10 ថ្ងៃធ្វើការ (រួមទាំងថ្ងៃបុណ្យដែលចំថ្ងៃធ្វើការផង) មុនពេលអ្នកដកកូនចេញពីសាលារដ្ឋ, អ្នកមិនបានផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅមណ្ឌលអប់រំអំពីពត៌មាននោះ;
2. ប្រសិនបើ, មុនពេលអ្នកដកកូនចេញពីសាលារដ្ឋ, មណ្ឌលអប់រំបានផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់អ្នក, អំពីគោលបំណងរបស់ខ្លួនក្នុងការវាយតំលៃកូនអ្នក (រួមទាំងមាន សេចក្តីអះអាងអំពីគោលបំណងនៃការវាយតំលៃដែលសមស្របនិងសមហេតុផល ផង), ប៉ុន្តែអ្នកមិនបានឲ្យកូនមានការវាយតំលៃនោះ; **ឬ**
3. បន្ទាប់ពីការរកឃើញរបស់តុលាការថា ទង្វើរបស់អ្នកគឺមិនសមហេតុផល ។

ប៉ុន្តែ, ការចំណាយនៃការសង:

1. មិនត្រូវកាត់បន្ថយឬបដិសេធដោយការខកខានមិនផ្តល់ការជូនដំណឹងឡើយ ប្រសិនបើ: (a) សាលាបានរាំងអ្នកមិនឲ្យផ្តល់ការជូនដំណឹងនោះ; (b) អ្នកមិនបានទទួលការជូនដំណឹងអំពីការទទួលខុសត្រូវរបស់អ្នក ក្នុងការផ្តល់ការជូនដំណឹង ដូចបានរៀបរាប់ខាងលើ; ឬ (c) ការអនុវត្តន៍តាមតម្រូវការខាងលើ គង់នឹងបណ្តាលឲ្យមានរបួសស្នាមរាងកាយដល់កូនអ្នក; **និង**
2. មិនអាច, តាមការសំរេចរបស់តុលាការ ឬមន្រ្តីសវនាការម្នាក់, កាត់បន្ថយឬបដិសេធ ដោយសារការខកខានរបស់មាតាបិតាក្នុងការផ្តល់ការជូនដំណឹងដែលតម្រូវឲ្យមាន ប្រសិនបើ: (a) មាតាបិតាមិនចេះអក្សរ ឬមិនសរសេរភាសាអង់គ្លេស; ឬ (b) ការអនុវត្តន៍តាមតម្រូវការខាងលើ គង់នឹងបណ្តាលឲ្យមានរបួសផ្លូវចិត្តធ្ងន់ធ្ងរដល់កូនអ្នក ។

ពត៌មានបន្ថែមអំពីកិច្ចការពារតាមនីតិវិធីរបស់អ្នក អាចទទួលបានពីស្ថាប័នខាងក្រោមនេះ:

**នាយកដ្ឋានអប់រំបឋមសិក្សានិងមធ្យមសិក្សា រដ្ឋមីស៊ូរី**
**ផ្នែកអនុវត្តច្បាប់**
ទូរស័ព្ទ: 573-751-0699
ទូរសារ: 573-526-5946
TDD: 1-800-735-2966

**ផ្នែកច្បាប់ស្តីពីមាតាបិតា រដ្ឋមីស៊ូរី (MPACT)**
ទូរស័ព្ទ: 816-531-7070
ទូរសារ: 816-531-4777
TDD/Voice: 1-800-743-7634

**ខែសីហា ឆ្នាំ 2009**
**នាយកដ្ឋានអប់រំបឋមសិក្សានិងមធ្យមសិក្សា រដ្ឋមីស៊ូរី**

នាយកដ្ឋានអប់រំបឋមសិក្សានិងមធ្យមសិក្សា មិនរើសអើងពូជសាសន៍, ពណ៌សម្បុរ, ដើមកំណើតជាតិសាសន៍, ភេទ, ពិការភាព, ឬអាយុឡើយ ក្នុងកម្មវិធីនិងសកម្មភាពនានារបស់ខ្លួន ។ សំណួរផ្សេងៗទាក់ទិននឹងកម្មវិធីនានារបស់នាយកដ្ឋាន អាចសួរនាំបាននៅឯអគាររដ្ឋ

*Jefferson State Office Building, Title IX Coordinator, 5th Floor, 205 Jefferson Street, Jefferson City, MO 65102-0480; ទូរស័ព្ទលេខ 573-751-9619។ សំណួរផ្សេងៗទាក់ទិននឹងកម្មវិធីនានារបស់នាយកដ្ឋាន និង ទីតាំងរបស់នាយកដ្ឋាន, សកម្មភាព, និង សំភារ ដែលអាចប្រើបានដោយជនពិការ អាចសួរនាំបាននៅ Jefferson State Office Buildin, Civil Rights Compliance (Title VI/Title IX/504/ADA/Age Act), 5th Floor, 205 Jefferson Street, Jefferson City, Missouri 65102-0480; telephone number 573-526-4757 or Relay Missouri (800) 735-2966.*